# ប្រយោជន៍បីប្រការ



រៀបរៀងដោយ
ភិក្ខុបញ្ញាញាណ សាន សុជា

សម្រាប់ចែកជាធម្មទាន

# ប្រយោជន៍បីប្រការ

# មាតិការអត្ថបទ


| **ល.រ** | **ទំព័រ** |
|---|---|
| ពាក្យប្រារព្ធ ........................................ | ក |
| **ប្រយោជន៍៣ប្រការ** ............................ | ១ |
| I.**ទិដ្ឋធម្មិកត្ថប្រយោជន៍** ...................... | ៤ |
| សម្បទា៤យ៉ាង ...................................... | ៥ |
| ឧដ្ឋានសម្បទា ...................................... | ៦ |
| អារក្ខសម្បទា ...................................... | ១៧ |
| វិធីថែរក្សាទ្រព្យ៤យ៉ាង ............................ | ២៣ |
| កល្យាណមិត្តតា ...................................... | ៣១ |
| មិត្តមិនគួរសេពគប់៤យ៉ាង ......................... | ៣២ |
| មិត្តគួរសេពគប់៤យ៉ាង ............................ | ៤៣ |
| សមជីវិតា ............................................ | ៥៥ |
| ហេតុគួរចាយទ្រព្យ៤យ៉ាង ........................ | ៦០ |
| ទិដ្ឋធម្មិកត្ថប្រយោជន៍ជាប្រយោជន៍ថ្នាក់ក្រោម . | ៦៧ |
| II.**សម្បរាយិកត្ថប្រយោជន៍** .............. | ៦៩ |
| សម្បទា៤យ៉ាង ...................................... | ៧៤ |
| សទ្ធាសម្បទា ........................................ | ៧៥ |
| វិបត្តិរបស់ឧបាសកឧបាសិកា៥យ៉ាង ............ | ៧៩ |
| សម្បត្តិរបស់ឧបាសកឧបាសិកា៥យ៉ាង ........... | ៨០ |
| សីលសម្បទា .......................................... | ៨៣ |
| ចាគសម្បទា .......................................... | ៩៣ |
| សប្បុរិសទាន៥យ៉ាង ................................ | ៩៤ |
| បញ្ញាសម្បទា ........................................ | ១០២ |
| ហេតុនាំឱ្យកើតបញ្ញា៣យ៉ាង ...................... | ១០៥ |
| អានិសង្សនៃការស្តាប់ធម៌៥យ៉ាង ................ | ១០៦ |

បរិញ្ញា៣ ................................................ ១១៥
សម្បរាយិកត្ថប្រយោជន៍ជាប្រយោជន៍ថ្នាក់កណ្តាល .១២១
**III.បរមត្ថប្រយោជន៍** ........................... ១២៣
និព្វានធាតុមាន២យ៉ាង ................................ ១២៦
សឧបាទិសេសនិព្វានធាតុ ............................... ១២៦
អនុបាទិសេសនិព្វានធាតុ ............................... ១៣៥
និព្វានជាទិសដៅចុងក្រោយនៃជីវិត ................. ១៣៨
លំដាប់នៃប្រយោជន៍ទាំង៣ .......................... ១៤១
អ្នកមានឧបការៈជួយពិនិត្យអក្ខរាវិរុទ្ធ ............. ១៤៣
ឈ្មោះសៀវភៅនិងអត្ថបទដែលបានរៀបរៀង..... ១៤៤
ប៉ុស្តិ៍វិទ្យុដែលកំពុងផ្សព្វផ្សាយ ......................... ១៤៥



# ពាក្យប្រារព្ធ

ពាក្យថា **មនុស្ស** មកពី **មនះ** ប្រែថា ចិត្ត និង **ឧស្សៈ** ប្រែថា ខ្ពស់ រួមសេចក្តីទៅមានន័យថា សត្វដែលមានចិត្តខ្ពស់។ សត្វដែលមានចិត្តខ្ពស់ សំដៅយកសត្វដែលមានលក្ខណៈល្អទាំងផ្លូវកាយ ផ្លូវវាចា និងផ្លូវចិត្ត ជាងសត្វតិរច្ឆាន ហើយព្រមទាំងអាចបំពេញ នូវប្រយោជន៍គ្រប់ប្រការបាន។

តម្លៃរបស់មនុស្ស មិនមែនសំដៅត្រង់រូបរាងស្រស់ស្អាតនោះទេ តាមសេចក្តីពិត គឺសំដៅតែទៅលើចំណេះដឹង សមត្ថភាព និងការ

ប្រព្រឹត្តប៉ុណ្ណោះ ជាពិសេសគឺការប្រព្រឹត្តឱ្យបានជាប្រយោជន៍ដល់ខ្លួនឯង និងអ្នកដទៃ ប្រៀបបីដូចជាដួងប្រទីបដែលឆេះឡើងហើយ មានលក្ខណៈបំភ្លឺខ្លួនឯងផង និងជះពន្លឺដល់វត្ថុខាងក្រៅខ្លួនផង។

មាសប្រាក់ ជាវត្ថុស្រស់ល្អស្អាត និងមានតម្លៃ ថែមទាំងកម្ររកបានទៀតផង ទើបបានជាវត្ថុគឺមនុស្សលោកត្រូវការយ៉ាងខ្លាំង រហូតដល់អ្នកខ្លះពោលថា "មានប្រាក់មានអ្វីៗទាំងអស់" តែតាមការពិត ពាក្យនេះមិនទាន់ត្រឹមត្រូវទាំងស្រុងនោះទេ ព្រោះមាសប្រាក់ អាចដោះស្រាយ



ប្រយោជន៍បានដោយចំណែកខ្លះប៉ុណ្ណោះ ហើយប្រយោជន៍ ដែលនឹងអាចទទួលបានពីមាសប្រាក់នោះ ទាល់តែម្ចាស់ដឹងច្បាស់នូវតម្លៃរបស់វា ថែមទាំងចេះវិធីប្រើប្រាស់ឱ្យបានល្អផង បើមិនដូច្នោះទេ មាសប្រាក់នោះក៏មិនខុសអ្វីអំពីថ្មមួយដុំនោះឡើយ។

ដូចគ្នានេះដែរ ការកើតជាមនុស្ស គឺជាការក្រណាស់ ហើយលំបាកទៀតផង ព្រោះតែការកើតជាមនុស្សជាការក្រនេះហើយ ទើបបានជាជីវិតមនុស្សនេះ មានតម្លៃណាស់សម្រាប់មនុស្សគ្រប់គ្នា។ ប៉ុន្តែថ្វីបើជីវិតមនុស្សមានតម្លៃ

អ្វីជាប្រយោជន៍ អ្វីជាហេតុឱ្យសាបសូន្យប្រយោជន៍ ហេតុដែលនាំឱ្យសាបសូន្យប្រយោជន៍គួរលះបង់ ហេតុដែលនាំឱ្យកើតប្រយោជន៍គួរចម្រើន រួមជាមួយនឹងសមត្ថភាពនិងការព្យាយាមតស៊ូផង។

សូមមនុស្សគ្រប់គ្នា ប្រើប្រាស់ជីវិតដ៏ថ្លៃនេះ សម្រាប់សាងប្រយោជន៍ឱ្យបានសម្រេចគ្រប់ប្រការចុះ។

-សូមឧទ្ទិសនូវបុណ្យកុសល ដែលកើតឡើងអំពីការងារធម្មទាននេះថ្វាយចំពោះ សម្តេចព្រះសង្ឃរាជ ជោតញ្ញាណោ **ជួន‿ណាត** ដែល



យ៉ាងនេះហើយក៏ដោយ ក៏មិនទាន់ប្រាកដថាមានសភាពល្អប្រសើរគ្រប់អន្លើ សម្រាប់មនុស្សគ្រប់គ្នានោះឡើយ លក្ខណៈសំខាន់គឺថាតើគេចេះប្រើប្រាស់ជីវិតនេះឱ្យមានប្រយោជន៍ ឬមួយក៏អត់ ប្រសិនបើគេមិនចេះប្រើប្រាស់ឱ្យបានល្អទេ ជីវិតមនុស្សនេះ ពិតជាអន់ជាងត្រីកំភ្លាញសម្រាប់ធ្វើប្រហុកដោយពិតប្រាកដ។

គ្រប់ប្រយោជន៍ទាំងអស់ មិនមែនជាកម្មសិទ្ធិដាច់មុខ សម្រាប់នរណាម្នាក់នោះទេ តាមពិតគឺជារបស់សាធារណៈ សម្រាប់សត្វលោកគ្រប់គ្នា ឱ្យតែសត្វលោកនោះស្គាល់ច្បាស់ថា

ជាវីរបុរសក្នុងចិត្តនៃខ្ញុំ និងបូរាណបណ្ឌិតខ្មែរគ្រប់ជំនាន់។

-សូមឧទ្ទិសចំពោះ ព្រះតេជព្រះគុណ ព្រះនាម **ញៀម ទ៉ាន់** ជាព្រះគ្រូឧបជ្ឈាយ៍របស់ខ្ញុំ និងលោកគ្រូអាចារ្យទាំងឡាយរបស់ខ្ញុំ។

-សូមជូនចំពោះញោមប្រុស **សាន-នុយ** និងញោមស្រី **អៀង-ចែម** ដែលកំពុងមានជីវិតនៅឡើយ និងពពួកញាតិក្នុងសង្សារវដ្តទាំងអស់។

មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្ន ឃុំរលាប ស្រុកសំពៅមាស

ខេត្តពោធិ៍សាត់ ប្រទេសកម្ពុជា

ថ្ងៃសុក្រ ៦រោច ខែបុស្ស ឆ្នាំរកា សប្តស័ក ព.ស២៥៤៩

**ភិក្ខុវជិរប្បញ្ញោ សាន-សុជា**



## ប្រយោជន៍៣ប្រការ

ពាក្យថា "**ប្រយោជន៍**" ដែលបញ្ញត្តិប្រើប្រាស់ជាភាសាខ្មែរនេះ ជាពាក្យចេញមកពីភាសាបាលីថា "**បយោជនៈ**" ភាសាសំស្រ្កឹតថា "**ប្រយោជន៍**" សំដៅសេចក្តីថា "ផល ឬកម្រៃដែលសមប្រកប ផលដែលគួរប្រាថ្នា ឬថាអ្វីៗដែលគេត្រូវការ, ដែលគេប្រកបទៅកើតការ, ផលដែលសម្រេចអំពីការប្រកប"។

ពាក្យថា "ប្រយោជន៏" នេះ ក្នុងភាសាបាលីមានពាក្យសម្រាប់ហៅច្រើន ជួនកាលហៅថា"**អត្ថះ**" ប្រែថា"ផល" ឬ "សេចក្តីចម្រើន"

ទើបបានជានៅក្នុងធម៌ដែលជាប្រយោជន៍ លោកប្រើពាក្យថា "**ទិដ្ឋធម្មិកត្ថៈ**" ជាដើម ជូនកាលហៅថា "**ហិតៈ**" ប្រែថា "ប្រយោជន៍" ឬថា "គុណ" ដូចពាក្យដែលលោកពោលថា"**អត្តហិតៈ**" ជាដើម។ ពាក្យដែលបានលើកឡើងមកនេះ គ្រាន់តែផ្សេងគ្នាដោយតួអក្សរប៉ុណ្ណោះ ប៉ុន្តែមានអត្ថន័យដូចគ្នា គឺសំដៅត្រង់ផលប្រយោជន៍ដែលនាំឱ្យសម្រេចបាននូវសេចក្តីសុខ សមតាមសេចក្តីប្រាថ្នា។

ពាក្យថាប្រយោជន៍ មានសេចក្តីច្រើនយ៉ាង និងមានសេចក្តីអធិប្បាយក៏ផ្សេងៗគ្នា តែបើ



សរុបឱ្យខ្លីមកមាន៣ប្រការគឺ

**១.ទិដ្ឋធម្មិកត្ថប្រយោជន៍** = ប្រយោជន៍ក្នុងបច្ចុប្បន្ន អាចសង្កេតឃើញបានដោយងាយ។

**២.សម្បរាយិកត្ថប្រយោជន៍** =ប្រយោជន៍ក្នុងបរលោក ទាល់តែមានទិដ្ឋិត្រង់ ហើយព្រមទាំងចេះដឹងច្បាស់លាស់ ក្នុងរឿងកម្មផល ទើបអាចឃើញបាន។

**៣.បរមត្ថប្រយោជន៍** = ប្រយោជន៍ គឺព្រះនិព្វាន ទាល់តែមានភ្នែកគឺបញ្ញា ទើបអាចឃើញបាន។

## I **ទិដ្ឋធម្មិកត្ថប្រយោជន៍**(១)

ប្រយោជន៍ក្នុងបច្ចុប្បន្ន

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែង ចំពោះទីឃជាណុមាណព កាលចូលទៅក្រាបទូលព្រះអង្គថា ខ្ញុំព្រះអង្គជាគ្រហស្ថ ជាអ្នកគ្រប់គ្រងផ្ទះសម្បែង មានបុត្រភរិយា ត្រូវការស្វែងរកទ្រព្យដើម្បីនឹងចិញ្ចឹមគ្រួសារ, កាលបើយ៉ាងនេះ សូមព្រះអង្គទ្រង់សំដែងនូវធម៌ណាមួយ សម្រាប់ជនជាគ្រហស្ថក្នុងបច្ចុប្បន្ននេះ ព្រមទាំងធម៌ដែលគួរប្រតិបត្តិ សម្រាប់កាលក្នុងបរលោកផង។ ក្នុងគ្រានោះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងអំពីអត្ថប្រយោ-

១-អង្គុត្តរនិកាយ អដ្ឋកនិបាត សទ្ធានវគ្គ បិដកលេខ៤៨ ចាប់ពីទំព័រ២៤៣តទៅ។



ជន៍ ទាំងបច្ចុប្បន្ននិងបរលោក។ ប្រយោជន៍ក្នុងបច្ចុប្បន្នមាន៤ប្រការគឺ

**១.ឧដ្ឋានសម្បទា** ការដល់ព្រមដោយសេចក្តីប្រឹងប្រែងក្នុងកិច្ចការគ្រប់យ៉ាងដើម្បីរកទ្រព្យសម្បត្តិ។

**២.អារក្ខសម្បទា** ការដល់ព្រមដោយកិច្ចថែទាំរក្សាទ្រព្យសម្បត្តិដែលរកបានហើយ។

**៣.កល្យាណមិត្តតា** ភាពជាអ្នកសេពគប់មិត្តល្អ។

**៤.សមជីវិតា** ភាពជាអ្នកមានជីវិតស្មើល្អ។

## ១.ឧដ្ឋានសម្បទា

កិច្ចការប្រឹងប្រែងរកទ្រព្យសម្បត្តិ គឺជាកាតព្វកិច្ចដ៏សំខាន់សម្រាប់ឃរាវាស អ្នកនៅគ្រប់គ្រងផ្ទះគ្រប់គ្នា។

ព្រះពុទ្ធជាម្ចាស់ ទ្រង់បានប្រៀនប្រដៅឱ្យមនុស្សគ្រប់គ្នា មានសេចក្ដីប្រឹងប្រែងបំពេញការងារតាមតួនាទីរបស់ខ្លួន ព្រមទាំងឱ្យលះបង់នូវភាពទម្រន់ និងការខ្ជិលច្រអូសគ្រប់ប្រការទៀតផង។

នៅក្នុងខុទ្ទកនិកាយ សុត្តនិបាត ឧរគវគ្គ បរាភវសូត្រទី ៦ គាថាទី ៣ ព្រះមានព្រះភាគ



ជាម្ចាស់ទ្រង់ត្រាស់តបបញ្ហារបស់ទេវតាថា

**"និទ្ទាសីលី សភាសីលី**
**អនុដ្ឋាតា ច យោ នរោ**
**អលសោ កោធបញ្ញាណោ**
**តំ បរាភវតោ មុខំ"**

ប្រែថា "អ្នកដេកលក់ច្រើនក្ដី និយាយច្រើនក្ដី មិនឃ្មាតខ្មី ខ្ជិលច្រអូសក្ដី ប្រាកដតែខាងក្រោធក្ដី នោះជាប្រធាននៃសេចក្ដីវិនាស"។

តាមពុទ្ធភាសិតខាងលើ ស្ដែងឱ្យឃើញបានថា អ្នកដែលខ្ជិលច្រអូស មិនប្រឹងប្រែងបំពេញកិច្ចការងារ មិនអាចធ្វើខ្លួនឯងឱ្យក្លាយជា

មនុស្សមានប្រយោជន៍ សម្រាប់សង្គមជាតិផង ថែមទាំងមិនអាចធ្វើខ្លួន ឱ្យក្លាយទៅជាពុទ្ធបរិស័ទដ៏ល្អផង ព្រោះមិនអាចញុំាងព្រះហឫទ័យរបស់ព្រះសាស្ដាឱ្យពេញបាន។

ទ្រព្យសម្បត្តិ មិនអាចកើតដល់មនុស្សខ្ជិលច្រអូសបានទេ។ អ្នកមិនមានការងារ គឺជាមនុស្សចង្អៀតលោក អន់ជាងឈើពុកអណ្ដែតតាមទឹកទៅទៀត ព្រោះឈើពុកនោះ កាលណាបើគេស្រង់យកមកអំពីទឹក គេគង់ប្រើឱ្យបានជាប្រយោជន៍ខ្លះមិនខាន ឯមនុស្សទម្រន់ មិនបំពេញកិច្ចការងារ ប្រៀបដូចជាបញ្ចើក្អែក បានត្រឹមតែ



រំខានអ្នកដទៃប៉ុណ្ណោះ។

ព្រះពុទ្ធសាសនា បានសំដែងសង្កត់ធ្ងន់ទៅលើ**កម្ម**និង**ផល**។ **កម្ម**គឺជាការងារដែលសត្វលោកត្រូវប្រព្រឹត្ត **ផល**គឺអ្វីដែលសម្រេចបានមកអំពីការប្រព្រឹត្តនោះឯង។ ដូច្នេះ ការសំដែងអំពីកម្មផល មិនមែនជាការសំដែងធ្វើឱ្យមនុស្សទន់ខ្សោយស្មារតីនោះទេ តាមពិតរឹតតែធ្វើឱ្យមនុស្សមានស្មារតី យកចិត្តទុកដាក់បំពេញយ៉ាងពេញទំហឹងនូវការងារដែលខ្លួនកំពុងធ្វើ ថែមទាំងមានទំនុកចិត្តថា ការដែលនឹងធ្វើឱ្យខ្លួនឯងក្លាយជាមនុស្សថោកទាបឬថ្លៃថ្នូរនោះ គឺអាស្រ័យទៅលើ

ការងារដែលខ្លួនឯងកំពុងប្រព្រឹត្តនោះឯង ដោយមិនប្រគល់វាសនាឱ្យទេវតា ឬអាទិទេពណាជាអ្នកសម្រេចនោះឡើយ ។

ការងារអាចបែងចែកសត្វលោក ឱ្យថ្លៃថ្នូរ ឬថោកទាបបាន ដូច្នេះសូមឱ្យមនុស្សគ្រប់គ្នាប្រឹងប្រែងប្រកបការងារចិញ្ចឹមជីវិតណា ដែលល្អប្រាសចាកទោស ដែលហៅថា "សម្មាអាជីវៈ" រួមជាមួយនឹងសេចក្តីសន្តោស ចេះត្រេកអរនឹងលទ្ធផល ដែលសម្រេចបានអំពីការងារដែលល្អនោះផង ។

គប្បីជ្រាបថា មិនមានការសម្រេចណា



ដោយមិនអាស្រ័យ នឹងការតស៊ូបំពេញកិច្ចការងារនោះទេ គ្រាន់តែប្លែកត្រង់ថា ជួនកាលក៏សម្រេចមកអំពីការងារបច្ចុប្បន្ន ជួនកាលក៏សម្រេចមកអំពីការងារក្នុងអតីតៈប៉ុណ្ណោះ ។ ការបានយល់ដឹងអំពីផលរបស់ការងារយ៉ាងនេះ អាចធ្វើឱ្យយើងចេះទទួលស្គាល់គ្រប់លទ្ធផលនៃការងារ ដោយសេចក្តីត្រជាក់ចិត្ត បើទុកជាផលនៃការងារនោះបានតិច ឬក៏ច្រើនយ៉ាងណាក៏ដោយ ។

តាមទស្សនៈខ្លះយល់ថា ការគោរពជឿតាមពាក្យប្រៀនប្រដៅ របស់ព្រះសម្មាសម្ពុទ្ធបានធ្វើឱ្យមនុស្សក្រ ឬទន់ខ្សោយស្មារតី គ្មាន

ជំហានឈានទៅរកសេចក្ដីចម្រើនរុងរឿង។ ការដែលគេយល់យ៉ាងនេះ មានប្រក្រតីពោលយ៉ាងនេះ ក៏គ្មានអ្នកណាអាចហាមឃាត់គំនិត ឬពាក្យពោលរបស់គេបានឡើយ ព្រោះគេមិនទាន់បានសិក្សា នូវពាក្យបង្រៀនរបស់ព្រះសម្មាសម្ពុទ្ធឱ្យបានច្បាស់លាស់ប៉ុណ្ណោះ គេជឿតាមតែភ្នែកនិងត្រចៀករបស់គេប៉ុណ្ណោះ គេមិនបានបើកភ្នែកបញ្ញាដើម្បីសិក្សាស្រាវជ្រាវ រាវរកសេចក្ដីពិតចាកព្រះសាសនានេះឡើយ ប្រសិនបើគេកុំជឿលើភ្នែកនិងត្រចៀករបស់គេពេក ហើយវិលមកសិក្សាព្រះពុទ្ធវចនៈឱ្យបានល្អិតល្អន់ មួយរយ



សឹងតែរាប់ដល់មួយពាន់ គឺថាគេនឹងអាចបោះបង់នូវគំនិតនេះ និងការពោលយ៉ាងនេះ ហើយមានតែការពោលសរសើរនូវពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធជាម្ចាស់មិនដាច់ពីមាត់មិនខានឡើយ។

នៅក្នុងខុទ្ទកនិកាយ តិកនិបាត ថេរគាថា មាតង្គបុត្តត្ថេរគាថា បានសំដែងថា

"ខណៈ រមែងប្រព្រឹត្តកន្លងនូវមាណពទាំងឡាយ ដែលមានការងារលះចោល (ដោយគិតអាងថា) ត្រជាក់ពេក ក្ដៅពេក ល្ងាចពេក។ បុគ្គលណាមួយ កាលធ្វើនូវកិច្ចរបស់បុរស មិនអើពើចំពោះត្រជាក់និងក្ដៅ ឱ្យក្រៃលែងជាង

ស្មៅ បុគ្គលនោះរមែងមិនសាបសូន្យចាកសេចក្តី សុខឡើយ.......”។

មនុស្សដែលមិនយកចិត្តទុកដាក់ នឹងកិច្ចការងារចិញ្ចឹមជីវិត អាងលេសយ៉ាងនេះយ៉ាងនោះ មិនក្រវើនក្រតើន ជាអ្នកដេកស្តាយយល់សប្តិជាដើម មិនខុសពីមនុស្សអត់ការងារនោះឡើយ ព្រោះមិនយូរប៉ុន្មាន សូម្បីមុខរបរដែលមានហើយ ក៏នឹងត្រូវដួលរលំទៅ ហើយនឹងក្លាយជាមនុស្សពិការទាំងដែលនៅមានអវយវៈល្អ។ ចង់ស្រណុក ហើយខ្វះខាតសេចក្តីព្យាយាម មិនអាចនឹងរួចអំពីសេចក្តីទុក្ខបានឡើយ។



សេចក្តីព្យាយាមប្រឹងប្រែង គឺជាពរដ៏ប្រសើរសម្រាប់មនុស្សគ្រប់គ្នា ព្រោះជាហេតុនាំសត្វលោកឱ្យរួចផុតទុក្ខលំបាកបាន ដូចដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សំដែងថា “**វីរិយេន ទុក្ខមច្ចេតិ**=ឆ្លងចាកសេចក្តីទុក្ខបានដោយសេចក្តីព្យាយាម”។

ការងារចិញ្ចឹមជីវិតខ្លះ ដូចជាការងារដាំដុះ ការងាររាជការ.... មើលពីក្រៅហាក់បីដូចជាការងារសម្រាប់ផ្ទាល់ខ្លួនម្នាក់ៗប៉ុណ្ណោះ ប៉ុន្តែតាមពិត ពិនិត្យឱ្យដិតដល់ទៅ គ្រប់ការងារចិញ្ចឹមជីវិតតាមផ្លូវសុចរិតទាំងអស់ សុទ្ធតែប្រព្រឹត្តទៅ

ជាប្រយោជន៏ដល់ខ្លួនឯងផង និងជាកិត្តិយសរបស់ប្រទេសជាតិទាំងមូលផង ព្រោះគេអាចដឹងថា ប្រទេសមួយរីកចំរើន គឺគេវាស់កម្រិតជីវភាពរស់នៅរបស់ប្រជាជននោះឯង។

សូមមនុស្សគ្រប់គ្នា មានការងាររបស់ខ្លួនជាទីពឹង សូមកុំពឹងដង្ហើមអ្នកដទៃដកឱ្យសោះ។

> ពាក្យថាសំណាង កើតពីការសាង ប្រកបកិច្ចការ
> ដោយក្តីព្យាយាម និងក្តីឧស្សាហ៏ លុះបានផ្លែផ្កា
> មានគុណគាប់ហោង។
>
> សាន~សុជា



## ២.អារក្ខសម្បទា

ការថែរក្សាការពារនូវទ្រព្យសម្បត្តិ ដែលខិតខំរកបានមកហើយឱ្យគង់វង្សល្អ គឺសំដៅដល់ការសន្សំសំចៃទ្រព្យទុក ឱ្យផុតពីសេចក្តីវិនាសអន្តរាយផ្សេងៗ។

ធម្មតាទ្រព្យដែលនឹងអាចគង់វង្សនៅ ឬចម្រើនឡើងបាន ក៏ដោយអាស្រ័យម្ចាស់ទ្រព្យចេះថែរក្សា ចេះចាយ ចេះប្រើ។ ឯការរក្សានោះសំដៅដល់ការចេះទុកដាក់ ចេះថ្នម ចេះជួសជុល និងចេះកែខៃឱ្យមានផលចម្រើនតទៅ។

តួនាទីកូនប្រុសស្រីចំពោះមាតាបិតា មាន

៥យ៉ាង ក្នុងបណ្ដាតួនាទី៥យ៉ាងនោះ មានមួយយ៉ាងដែលព្រះមានព្រះភាគទ្រង់បង្រៀន ឱ្យកូនប្រុសស្រីធ្វើខ្លួន ឱ្យសមជាអ្នកទទួលមតិក។ មាតាបិតា ចាប់តាំងពីពេលកាន់ដៃគ្នាកសាងគ្រួសារដំបូង មានការខិតខំប្រឹងប្រែងរកទ្រព្យខ្លាំងជាងពេលដែលខ្លួននៅទំនេរ ព្រោះចង់មានជីវភាពសមរម្យនឹងគេ ជាងនេះទៅទៀត តែងនឹកគិតទៅដល់អនាគតកូនប្រុសស្រីជាទីស្រឡាញ់របស់ពួកគាត់ ខ្លាចក្រែងមិនមានអ្វីចិញ្ចឹមកូន និងមិនមានអ្វីចែកឱ្យកូន ទើបបានជាការងារកាន់តែច្រើនឡើងសម្រាប់ពួកគាត់ទាំងពីរនាក់។



កាលកូនប្រុសស្រីនឹកឃើញ ទៅដល់ញើសឈាម និងទឹកចិត្តរបស់មាតាបិតាឱ្យបានរឿយៗយ៉ាងនេះ សូម្បីទ្រព្យដែលមាតាបិតាចែកឱ្យនោះ មិនច្រើនក៏ដោយ កូនប្រុសស្រីត្រូវតែរក្សាឱ្យបានល្អជាទីបំផុត ព្រមទាំងចេះកែខៃនូវមតិកនោះឱ្យមានប្រយោជន៏ឡើង ទើបសមគួរជាអ្នកទទួលនូវមតិកនោះ ព្រោះក្នុងទ្រព្យមតិកទាំងនោះ មានញើសឈាមរបស់មាតាបិតា ព្រមទាំងបង្កប់នូវមេត្តាព្រហ្មវិហារ ដ៏មានជម្រៅទៀតផង។

ការថែរក្សាទ្រព្យ ដែលជាមតិករបស់

មាតាបិតាក្តី ការថែទាំទ្រព្យសម្បត្តិដែលបានមក ដោយការខិតខំប្រឹងប្រែងរកដោយខ្លួនឯងក្តី គឺជា កាតព្វកិច្ច ដែលជនជាយរាវាសគ្រប់ៗគ្នាត្រូវតែ ធ្វើ បើមិនដូច្នោះទេ មុខជានឹងក្លាយទៅជាញាតិ ផៅរបស់អ្នកសុំទានមិនខានឡើយ។

ក្នុងអតីតកាល ព្រះបរមពោធិសត្វធ្លាប់ កើតជាសេដ្ឋីអ្នកមានទ្រព្យច្រើន ព្រះអង្គតែងធ្វើ បុណ្យសុន្ទរ៍ទានជារឿយៗ មុនពេលព្រះអង្គអស់ ជីវិត បានប្រគល់ទ្រព្យទាំងអស់ឱ្យកូនប្រុសរបស់ ព្រះអង្គ ហើយក៏ស្លាប់រួចបដិសន្ធិជាសក្កទេវរាជ។ ឯកូនប្រុសរបស់ព្រះអង្គ ជាមនុស្សវង្វេងនឹងទ្រព្យ



ងប់នឹងអបាយមុខ មិនចេះថែរក្សាមតិករបស់បិតា ឱ្យបានល្អ មិនយូរប៉ុន្មានក៏បានក្លាយជាអ្នកសុំទាន។

ចំណែកសក្កទេវរាជ ដែលធ្លាប់ជាបិតា បានទតឃើញដូច្នោះ មានព្រះទ័យអាណិតណាស់ បាននាំយកឆ្នាំងទិព្វមួយទៅប្រគល់ឱ្យ ដោយ ពោលផ្តាំថា "ម្នាលបា ឆ្នាំងទិព្វនេះមាន អានុភាពណាស់ កាលបើបាត្រូវការអ្វី ចូរបាយកពី ក្នុងឆ្នាំងទិព្វនេះចុះ តែយើងសូមផ្តាំអ្នកថា ចូរអ្នក ថែរក្សាឆ្នាំងនេះឱ្យបានល្អ កុំឱ្យបែកឱ្យសោះ ប្រសិនបើបែក ឆ្នាំងនេះមុខជាប្រើការលែងបាន ហើយ"។

កូនប្រុសនោះជាមនុស្សប្រមាទ មិនបាន ចាំនូវបណ្តាំរបស់បិតា ពេលមួយបបួលមិត្តភក្តិ ផឹកស្រាស្រវឹង រួចក៏យកឆ្នាំងនោះបោះលេងជាល្បែង ឆ្នាំងទិព្វនោះក៏ធ្លាក់បែក ហើយខ្លួនឯងក៏ក្លាយជាអ្នកសុំទានម្តងទៀត មានសភាពកំសត់ដរាបដល់អស់ជីវិតទៅ ។

ការដែលសំដែងអំពី ការថែរក្សាទ្រព្យឱ្យគង់វង្សមិនឱ្យបាត់បង់ មិនមែនជាការខ្វាស់ទៅនឹងកម្មផលនោះទេ ព្រោះលទ្ធផលដែលល្អប្រសើរដែលគួរទទួលបាននោះ កើតឡើងដោយកត្តា២យ៉ាងសំខាន់គឺ បុណ្យដែលបានធ្វើហើយក្នុងកាល



អតីតៈ និងការប្រកបក្នុងបច្ចុប្បន្ន បើមានតែសំណាងព្រោះសាងពីអតីតៈ តែខ្ជះខ្ជាក់ដែលសាងបច្ចុប្បន្ន ក៏ប្រយោជន៍ដែលទទួលបាននោះ មិនអាចឱ្យផលយ៉ាងពេញទំហឹងឡើយ ។

## វិធីថែរក្សាទ្រព្យ៤យ៉ាង

### ក/ ចេះស្វែងរករបស់ដែលបាត់

របស់ដែលបាត់ ជួនកាលបាត់ដោយអស់បុណ្យ ជួនកាលបាត់ដោយអកុសលបៀតបៀន ជួនកាលក៏បាត់ ដោយអាស្រ័យការធ្វេសប្រហែសនៃម្ចាស់របស់ ។ ប៉ុន្តែបើទុកជាទ្រព្យនោះត្រូវបាត់

បង់ទៅដោយប្រការណាក៏ដោយ ក៏ត្រូវតែស្វែងរកដែរ ព្រោះថាជួនកាលអាចឃើញមកវិញដោយពិតប្រាកដ តែថាបើរកមិនឃើញទេ ត្រូវចេះទទួលស្គាល់ការពិតផង ត្រូវចេះហាមប្រាមចិត្តដែលសោកស្តាយខ្លាំងៗ និងសេចក្តីក្រោធខឹងកុំឱ្យកើតឡើង បើមិនដូច្នោះទេ យើងមិនមែនបាត់បង់ត្រឹមតែទ្រព្យប៉ុណ្ណោះទេ ទ្រព្យដែលបាត់នោះ បានឆក់យកនូវសេចក្តីសុខរបស់យើងទៅជាមួយផងដោយពិត។

### ខ/ ចេះជួសជុលរបស់ដែលខូចឬចាស់

វត្ថុសម្រាប់ប្រើប្រាស់ទាំងអស់ សុទ្ធតែ



ត្រូវប្រែប្រួលនិងចាស់គ្រាំគ្រា ទីបំផុតនឹងត្រូវខូចខាតទៅដោយឥតមានសេសសល់ឡើយ ប៉ុន្តែថ្វីបើយ៉ាងនេះហើយក៏ដោយ បើចេះថ្នមវាក៏អាចប្រើប្រាស់បានកាលយូរអង្វែង មិនសូវខាតប្រាក់ក្នុងការទិញរបស់ថ្មីមកប្រើជំនួស ហើយយើងអាចសន្សំប្រាក់សម្រាប់ទុកធ្វើជាដើមទុនក្នុងមុខរបរ ឬក៏អាចធ្វើអ្វីដែលជាប្រយោជន៍ផ្សេងទៀតបាន។

របស់របរខ្លះ មិនមែនថាចាស់រហូតដល់ប្រើលែងបាននោះទេ គ្រាន់តែអន់រូបអន់រាងបន្តិចប៉ុណ្ណោះ ដូចជានៅក្នុងរឿងទូរស័ព្ទ ត្រឹមតែតម្លៃ ៧០ ឬ ៨០ ដុល្លា ក៏ល្មមសមគួរនឹងប្រើប្រាស់ក្នុង

ការទំនាក់ទំនងគ្នាបានដោយស្រួលទៅហើយ ប៉ុន្តែដោយចង់ដេញម៉ូតដេញសម័យ ត្រូវថែម ១០០ ឬ ២០០ ដុល្លាទៀតដើម្បីដូរយករបស់ថ្មី ទង្វើបែបនេះ មិនមែនត្រឹមតែដើម្បីប្រយោជន៍រស់នោះទេ គឺថាប្រាក់ដែលបន្ថែមពីលើនោះ គឺជាការបូជាតណ្ហាដោយពិត។ ចំណែកភិក្ខុសាមណេរ ត្រូវតែគិតអំពីបញ្ហានេះ កុំភ្លេចខ្លួនឱ្យសោះ។

ប្រុសសង្ហា មិនមែនដោយសារទូរស័ព្ទទេ បូរាណបានពោលថា "**ស្រីស្រស់ព្រោះចរិយា ប្រុសសង្ហាព្រោះវិជ្ជា**" ចំណែកបព្វជិត ក៏មិនខុសពីស្រ្តីប៉ុន្មានដែរ បើមានតែវិជ្ជាខ្វះចរិយា ដូច



ផ្លែល្ហាល្អតែក្រៅ។

របស់ខ្លះចាស់ទៅមែន តែនៅមានប្រយោជន៍ខ្លះ ហើយបើរបស់នោះមិនចេះយំទារចំណីស៊ីទេ គប្បីតែថែរក្សាទុកឱ្យបានល្អ ជួនកាលពេលនេះយើងមិនត្រូវការ ដោយអាងថា មានគ្រប់គ្រាន់ហើយ ប៉ុន្តែថ្ងៃណាមួយយើងនឹងអាចត្រូវការវាជាក់ជាមិនខាន។

## គ/ **បរិភោគល្មមប្រមាណ**

ការបរិភោគល្មមប្រមាណ សំដៅដល់ការចេះសន្តោសក្នុងការបរិភោគ មិនល្មោភតាមតែចំណង់ ព្រោះយើងមិនមែនបរិភោគតែមួយពេល

ហើយឈប់នោះទេ ត្រូវគិតទៅដល់ថ្ងៃក្រោយផង ក្រែងលោរកមិនបានដូចថ្ងៃនេះ។

### ឃ/ មិនតាំងបុរសឬស្ត្រីទ្រុស្តសីលជាធំ

បុរសឬស្ត្រី ដែលទ្រុស្តសីលក្នុងទីនេះ សំដៅយកបុរសស្ត្រីណា ដែលមិនមានការស្មោះត្រង់ ហើយចូលចិត្តប្រព្រឹត្តអបាយមុខ ដូចជាល្បែងស៊ីសងជាដើម។ ការដែលប្រគល់ឱ្យបុរសឬស្ត្រីប្រភេទនេះ ឱ្យជាអ្នកកាន់កាប់ទ្រព្យសម្បត្តិ តែងតែមានការវិនាសអន្តរាយមិនខានឡើយ ដូចនៅក្នុងខុទ្ទកនិកាយ សុត្តនិបាត ឧរគវគ្គ បរាភវសូត្រទី ៦ គាថាទី ១១ ព្រះមានព្រះភាគ



ទ្រង់ត្រាស់តបបញ្ហារបស់ទេវតាថា

**"ឥត្ថឹសោណ្ឌឹ វិកិរណឹ**
**បុរិសំ វាបិ តាទិសំ**
**ឥស្សរិយស្មឹ ឋបេតិ**
**តំ បរាភវតោ មុខំ"**

ប្រែថា "បុរសបុគ្គលតាំងស្ត្រីអ្នកលេងខ្ជះខ្ជាយ ឬបុរសបែបនោះដែរ ក្នុងឋានៈជាធំ នោះជាប្រធាននៃសេចក្ដីវិនាស"។

បុរសស្ត្រីដែលខ្ជះខ្ជាយដូច្នេះ ប្រៀបដូចជាកញ្ជើដែលមានបាតធ្លុះ បើទុកជាគេខំដាក់របស់បំពេញយ៉ាងណា ក៏មិនអាចពេញបានឡើយ។

សូម្បីភ្នំខ្ពស់គង់គេឡើងបាន   តស៊ូក្លាហានគង់បានជំនះ
សន្សំបារមីគង់បានតេជះ   ធ្វើរបងផ្ទះគង់បានសល់ទ្រព្យ ។

សាន សុជា



## ៣.កល្យាណមិត្តតា

ក្នុងគម្ពីរខុទ្ទកនិកាយ ខុទ្ទកបាឋ មង្គលសូត្រ ព្រះមានព្រះភាគទ្រង់ត្រាស់សំដែងអំពីមង្គលសិរីសួស្តីរបស់សត្វលោក មាន១០គាថា បើរាប់ជាមាតិកាមាន៣៨ប្រការ ។

ក្នុងបណ្តាមង្គលទាំង៣៨នោះ មាតិកាដំបូង ព្រះមានព្រះភាគជាម្ចាស់ទ្រង់ផ្តោតទៅលើការសេពគប់ជាសំខាន់ ដោយមាតិកាទី១ ព្រះអង្គទ្រង់ហាមប្រាមមិនឱ្យសេពគប់បុគ្គលពាល និងមាតិកាទី២ ទ្រង់បង្គាប់ឱ្យសេពគប់បុគ្គលដែលជាបណ្ឌិត ។

ការសេពគប់មិត្រ មិនមែនគ្រាន់តែដើម្បីឱ្យបានត្អិត្អាប៉ុណ្ណោះទេ គឺដើម្បីមានប្រយោជន៍សុខទាំងសងខាង ដូច្នេះត្រូវតែមានការគិតគូរឱ្យបានល្អិតល្អន់ទើបប្រសើរ ។

ដើម្បីធ្វើខ្លួន ឱ្យជាអ្នកមានកល្យាណមិត្រ ក៏ត្រូវតែសិក្សាឱ្យស្គាល់ថា ដូចម្តេចដែលជាបាបមិត្ត ដូចម្តេចដែលជាកល្យាណមិត្តឱ្យបានច្បាស់លាស់ជាមុនសិន ។

**មិត្តមិនគួរសេពគប់៤យ៉ាង**[១]

1.**មិត្តគិតតែប្រយោជន៍ផ្ទាល់ខ្លួន**

2.**មិត្តល្អតែសំដី**

១-គម្ពីរ ទីឃនិកាយ បាដិកវគ្គ បិដកលេខ១៩ ចាប់ពីទំព័រ៧៨ទៅ ។



3.**មិត្តនិយាយចាក់បណ្តោយ**

4.**មិត្តនាំឱ្យប្រព្រឹត្តផ្លូវវិនាស**

## 1.មិត្តគិតតែប្រយោជន៍ផ្ទាល់ខ្លួនមាន៤

ក-**មិត្ត ដែលចង់តែបាននូវប្រយោជន៍ផ្ទាល់ខ្លួន** គឺគិតតែប្រយោជន៍ផ្ទាល់ខ្លួន មិនគិតដល់ប្រយោជន៍មិត្ត ចេះត្រេកអរតែខាងបានអំពីមិត្ត តែមិនចេះបរិច្ចាគឱ្យមិត្តវិញទេ ។

ខ-**មិត្ត ប្រាថ្នារបស់ច្រើនដោយឱ្យរបស់តិចតួច** គឺថាកាលបើមានរបស់អ្វីឱ្យមិត្ត គឺគេឱ្យបន្តិចបន្តួចប៉ុណ្ណោះ តែគេចង់បានពីមិត្តមកវិញ

ច្រើន១ ដូចជាដាក់នុយដើម្បីស្ទូចត្រីអ៊ីចឹងឯង។

គ-**មិត្តដែលមិនជួយកិច្ចការមិត្ត នៅពេលដែលមិត្តមានភ័យ** ស៊ីសេចក្តីទៅនឹងភាសិតបូរាណថា "ចូលព្រៃសត្វសាហាវ ស្រែកអំពាវគ្នាមកជុំ បានស្ករឬទឹកឃ្មុំពួនសម្ងំឆីតែឯង"។

ឃ.**មិត្តដែលសេពគប់មិត្ត ព្រោះហេតុតែប្រយោជន៍ផ្ទាល់ខ្លួន** បុគ្គលប្រភេទនេះ គឺមិនបានសម្លឹងឃើញនូវគុណធម៌ និងទឹកចិត្តរបស់មិត្តនោះទេ គឺសម្លឹងឃើញតែយសសក្តិ និងទ្រព្យសម្បត្តិរបស់មិត្តប៉ុណ្ណោះ ដូចមានពាក្យថា "ហុតទឹកសម្លឹងកាក ទាញច្រវ៉ាក្រាកសំឡឹងត្រើយ"។



## 2.**មិត្តល្អតែសំដី៤យ៉ាង**

ក-**មិត្តទទួលរាក់ទាក់ដោយរបស់ ដែលកន្លងទៅហើយ** មិត្តប្រភេទនេះល្អតែមាត់ ដូចជានិយាយថា"ព្រឹកមិញនេះ ខ្ញុំមានខ្ទុរទុំច្រើនណាស់ ខ្ញុំទើបតែលក់អស់អម្បាញ់មិញនេះឯង បើមិត្តមកទាន់ពីព្រឹក ខ្ញុំនឹងឱ្យមិត្តខ្លះ"។

ខ-**មិត្តទទួលរាក់ទាក់ដោយរបស់ ដែលមិនទាន់មកដល់** បុគ្គលប្រភេទនេះ ចូលចិត្តសន្យាណាស់ តែមិនគោរពតាមពាក្យសន្យាទេ កាលកំណត់មកដល់ ចេះតែដោះខ្លួនដោយអាងលេសថាយ៉ាងនេះយ៉ាងនោះ។

គ-**មិត្តដែលសង្គ្រោះមិត្ត ដោយអំពើមិនជាប្រយោជន៍** បុគ្គលប្រភេទនេះនិយាយទៅកាន់មិត្ត ហាក់ដូចជាខ្លួនឯងមានចិត្តល្អ តែគ្មានបានការអ្វីទាំងអស់ ដូចជានិយាយថា "ទាស់តែខ្ញុំមានវិទ្យុតែ១ បើខ្ញុំមាន២ ខ្ញុំពិតជាឱ្យមិត្តឯង១ហើយ"។ *សូមផ្តាំផ្ញើទៅមនុស្សប្រភេទនេះថា "បើមិនជុះទេ សូមកុំផោមឱ្យភ្លែអរ"។*

ឃ-**មិត្ត ដែលមិត្តមានកិច្ចធុរៈជាបន្ទាន់ក៏សំដែងអាងរបស់ដែលខូចទៅហើយ** ដូចជាពេលដែលមិត្តមានធុរៈម្តាយឈឺធ្ងន់ ហើយពឹងឱ្យមិត្តជួយជូនទៅពេទ្យ ខ្លួនក៏ពោលឡើងថា "សោក



ស្តាយណាស់សម្លាញ់ ឡានខ្ញុំខូចបាត់ទៅហើយ បើមិនដូច្នោះទេ ខ្ញុំនឹងជូនទៅភ្លាម"។ *បើពិតជាមិត្តល្អមែន សូម្បីឡានរបស់ខ្លួនខូចមែនក៏ដោយក៏នៅតែរកមធ្យោបាយជូនទៅឱ្យទាល់តែបាន។*

## 3.មិត្តនិយាយចាក់បណ្តោយ៤យ៉ាង

ក-**មិត្ត ព្រមឱ្យមិត្តធ្វើបាប** ដូចជាព្រមឱ្យមិត្តសម្លាប់សត្វ ឬលួចទ្រព្យគេជាដើម។ អ្នកដែលព្រមឱ្យមិត្តធ្វើបាបដូច្នេះ គឺជាការបិទផ្លូវសួស្តី ហើយបើកផ្លូវអន្តរាយអោយមិត្តដោយប្រាកដ។

ខ. **មិត្ត ដែលព្រមឱ្យមិត្តធ្វើអំពើល្អ** ការដែលគេព្រមឱ្យមិត្តធ្វើល្អនោះ មិនសំដៅដល់ការ

អនុគ្រោះដោយចិត្តល្អទេ គ្រាន់តែនិយាយចាក់បណ្ដោយឱ្យពីរោះស្ដាប់តែប៉ុណ្ណោះ។

គ-**មិត្តនិយាយសរសើរមិត្ត តែក្នុងទីចំពោះមុខ** មនុស្សប្រភេទនេះ គេនិយាយល្អក្នុងទីចំពោះមុខមិត្ត មិនមែនដោយចិត្តល្អនោះទេ គោលបំណងគឺចង់តោងយកផលកម្រៃពីមិត្តប៉ុណ្ណោះ។

ឃ-**មិត្ត ពោលទោសមិត្តក្នុងទីកំបាំងមុខ** បុគ្គលប្រភេទនេះ គឺជាភេគដំបៅសង្គម គេមិនមានគំនិតស្ថាបនាមិត្តឱ្យបានល្អឡើយ ជាមនុស្សមិនចេះជួយការពារមិត្តឡើយ មានវាចាគួរឱ្យខ្ពើមជាងលាមក។



**4.មិត្តនាំឱ្យប្រព្រឹត្តផ្លូវវិនាសមាន៤យ៉ាង**

ក-**មិត្ត ជាសម្លាញ់អ្នកប្រកបរឿយៗនូវការផឹកទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទ** អ្នកផឹកទឹកស្រវឹងមិនសូវបាននាំមកនូវប្រយោជន៍ពិតប្រាកដ ដល់មិត្តឡើយ ព្រោះគេច្រើនតែនិយាយធូរនៅពេលដែលគេស្រវឹងប៉ុណ្ណោះ ដូចមានពាក្យនិយាយតៗគ្នាថា *"ស្វាងតឹង ស្រវឹងធូរ"*។

ខ-**មិត្ត ជាសម្លាញ់អ្នកប្រកបរឿយៗនូវការត្រាច់ទៅកាន់ច្រកល្ហកខុសកាល** ការដើរលេងយប់មិនជាការល្អទេ ជួនកាលអាចជាន់ដាន

ចោរទៀតផង។ បើនៅជាសិស្ស ត្រូវទុកពេលវេលាមើលមេរៀន ឬធ្វើលំហាត់វិញទើបប្រសើរ ត្រូវតាំងចិត្តថា *"អញត្រូវតែបានពិន្ទុល្អជានិច្ច"*។ បើជាប្តី ត្រូវតែនៅការពារផ្ទះសម្បែង ដើម្បីផ្តល់ភាពកក់ក្តៅដល់កូនប្រពន្ធ។ បើជាប្រពន្ធរឹតតែត្រូវគិតឱ្យណាស់អំពីបញ្ហានេះ ប្រយ័ត្នចាញ់សត្វបក្សី ព្រោះសត្វបក្សីមិនងាយភ្លេចពេលចូលទ្រនំឡើយ។

គ-**មិត្ត ជាសម្លាញ់អ្នកប្រកបរឿយៗក្នុងកិរិយាដើរមើលល្បែងមហោស្រព** ការដើរមើលមហោស្រព គឺជាការញៀនម្យ៉ាងដែលអ្នក



ត្រូវការប្រយោជន៍ត្រូវតែលះបង់ ព្រោះជាការខាតបង់ទាំងពេលវេលា ខាតបង់ទាំងទ្រព្យ។

ឃ-**មិត្ត ជាសម្លាញ់អ្នកប្រកបរឿយៗនូវល្បែងភ្នាល់ ដែលជាទីតាំងនៃសេចក្តីប្រមាទ** ការយកអ្នកលេងល្បែងជាមិត្ត សូម្បីពេលនេះយើងមិនទាន់ក្លាយជាអ្នកលេង តែយូរៗទៅ គង់តែរមាស់ដៃតាមគេមិនខាន កាលបើកើតរោគរមាស់ដៃហើយ មិនងាយគ្រូណាព្យាបាលជាឡើយ ទ្រព្យសម្បត្តិកប់ទុកទីណា ក៏ត្រូវវិនាសដែរ។

គ្រប់ប្រភេទនៃបុគ្គល ដែលបានរៀបរាប់មកខាងលើ សុទ្ធតែជាបុគ្គលដែលមិនគួរសេពគប់

ទាំងអស់ ត្បិតសភាពជាបុថុជ្ជន ហើយថែមទាំងមិនសូវបានស្តាប់ធមិរបស់សប្បុរសទៀត មិនអាចមានសតិសម្បជញ្ញៈគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងខ្លួនមិនឱ្យឆ្លងតាមគេបាននោះទេ ព្រោះប្រាជ្ញាស្មារតីនៅទន់ខ្សោយណាស់ ប្រៀបដូចជាដៃមានដំបៅ កាលបើលូកទៅក្នុងថ្នាំពិស ពិតជាជ្រាបចូលមិនខានឡើយ ដូច្នេះគួរតែកុំសេពគប់ឬកុំយកជាគ្នាទើបប្រសើរ ។

ក្នុងលោកនេះ មិនមែនមានតែមិត្តដែលមិនគួរសេពគប់នោះទេ ប្រសិនបើយើងមានគំនិតគិតចង់ស្វែងរកកល្យាណមិត្តហើយ មិនយូរមិន



ឆាប់គង់តែបានជួបមិនខាន តែសូមសិក្សាឱ្យស្គាល់នូវលក្ខណៈរបស់កល្យាណមិត្តផង ។

*4បើធ្វើខ្លួនជារុយ ពិតជាជួបរបស់ស្អុយមិនខាន ។*

តទៅនឹងរៀបរាប់អំពីមិត្ត ដែលគួរសេពគប់ សូមពុទ្ធបរិស័ទបានសិក្សាដោយល្អចុះ ។

## មិត្តគួរសេពគប់មាន៤ប្រភេទ

1. **មិត្តមានឧបការៈ**
2. **មិត្តរួមសុខទុក្ខ**
3. **មិត្តប្រាប់នូវប្រយោជន៍**
4. **មិត្តចេះមានចិត្តឈឺឆ្អាល**

## 1.មិត្តមានឧបការៈមាន៤យ៉ាង

ក-**មិត្តរក្សាមិត្ត ពេលដែលមិត្តធ្វេសប្រហែស** មនុស្សដែលល្អ កាលបើឃើញមិត្តបាត់បង់ស្មារតីនៅក្នុងរឿងអ្វីមួយ ដូចជានៅក្នុងរឿងការងារ ឬក៏ក្នុងការសិក្សាជាដើម ហើយធ្លោយខ្លួនប្រព្រឹត្តអបាយមុខផ្សេងៗ ក៏ជួយការពារ ឬក៏ជួយនិយាយដាស់តឿនមិត្ត ឱ្យមានស្មារតីឡើងវិញ មិនមែននិយាយតែអំពីខាងក្រោយនោះទេ។

ខ-**មិត្តរក្សាសម្បត្តិរបស់មិត្ត ដែលធ្វេសប្រហែស** មនុស្សយើងមានការធ្វេសប្រហែសស្មារតីជាធម្មតា ទើបបានជាត្រូវការមិត្តល្អជាគ្នា



ព្រោះមិត្តល្អ តែងតែជួយមើលថែទ្រព្យសម្បត្តិឱ្យយើង ក្នុងខណៈដែលយើងភ្លេចចោលនូវរបស់ផ្សេងៗ ឬក្នុងខណៈដែលយើងមិននៅផ្ទះជាដើម។

គ-**មិត្តជាទីពឹងពិតប្រាកដ នៅពេលដែលមិត្តមានគ្រោះភ័យ** មិត្តប្រភេទនេះតែងតែជួយអារកាត់នូវបញ្ហារបស់មិត្ត ឬក៏ជួយការពារមិត្តជានិច្ច ពេលមិត្តមានបញ្ហា តែងយកខ្លួនពាំងរួចពោលថា "មានខ្ញុំនៅហើយ សូមមិត្តកុំព្រួយ"។

ឃ-**មិត្ត កាលបើមិត្តមានកិច្ចចាំបាច់ដោយភោគៈហើយ ក៏ផ្តល់ទ្រព្យឱ្យលើសពីកម្រិតដែលមិត្តត្រូវការ** មិត្តប្រភេទនេះ ជាមិត្តមានចិត្ត

ទូលាយ តែងអនុគ្រោះមិត្តដោយចិត្តល្អ ដូចជាថា មិត្តមានកូនឈឺ ត្រូវការប្រាក់១០.០០០រៀល ដើម្បីព្យាបាលកូន ក៏ឱ្យដល់ទៅ១៥.០០០ ឬក៏ ២០.០០០រៀល ដោយចិត្តអនុគ្រោះ ព្រោះខ្លាចក្រែងមិនគ្រប់។

## 2.**មិត្តរួមសុខទុក្ខមាន៤យ៉ាង**

ក-**មិត្ត ប្រាប់នូវអាថិកំបាំងរបស់ខ្លួនដល់មិត្ត** មានរឿងអាថិកំបាំងខ្លះ មនុស្សយើងមិនអាចដោះស្រាយ ដោយខ្លួនឯងបានឡើយ ទើបត្រូវតែទម្លាយអាថិកំបាំងនោះ ប្រាប់ដល់មិត្ត ជូនកាលមិត្តនោះអាចជួយដោះស្រាយបាន ប៉ុន្តែ



កុំចេះតែនិយាយប្រាប់ ដោយមិនរើសមុខឱ្យសោះ ព្រោះអាចថានឹងមានបញ្ហាកាន់តែខ្លាំងឡើង។

ខ-**មិត្ត ដែលចេះជួយលាក់អាថិកំបាំងរបស់មិត្ត** មិត្តប្រភេទនេះប្រៀបបីដូចជាមាតាបិតាអីចឹងឯង មិនចេះតែនិយាយពីអាថិកំបាំងមិត្តប្រាប់គេឯងនោះទេ មានតែជួយការពារកិត្តិយសរបស់មិត្តទៀតផង។

គ-**មិត្តដែលមិនបោះបង់មិត្ត នៅពេលដែលមិត្តមានវិបត្តិ** នៅក្នុងជីវិតប្រចាំថ្ងៃ វិបត្តិតូចធំតែងកើតមានជាធម្មតា តែយើងអាចមានមិត្តរួមសុខទុក្ខជាគ្នា ព្រោះពាក្យថា **មិត្តរួមសុខទុក្ខ**

មិនមែនរួមតែសុខទេ ទុក្ខក៏រួមដែរ ។

ឃ-**មិត្ត ដែលសូម្បីជីវិតក៏ហ៊ានលះបង់ដើម្បីប្រយោជន៍មិត្ត** មិត្តប្រភេទនេះតែងតែជួយការពារប្រយោជន៍មិត្ត កុំថាឡើយត្រឹមអស់ទ្រព្យសម្បត្តិ ឬអវយវៈ សូម្បីដល់អស់ជីវិតក៏ហ៊ានលះបង់ដើម្បីមិត្តដែរ ។

## 3.មិត្តប្រាប់នូវប្រយោជន៍មាន៤យ៉ាង

ក-**មិត្ត ដែលចេះហាមប្រាមមិត្តមិនឱ្យធ្វើបាប** មិត្តដែលចេះហាមប្រាមមិត្តមិនឱ្យធ្វើអំពើអាក្រក់ ប្រៀបបីដូចជាកំពុងឃើញមិត្តដើរទៅកាន់ចំការមីន ហើយហាមប្រាមមិត្តមិនឱ្យដើរចូល



ទៅដូច្នោះឯង ព្រោះខ្លាចមិត្តគ្រោះថ្នាក់ ។

ខ-**មិត្ត ដែលចេះដឹកនាំមិត្តឱ្យធ្វើនូវអំពើល្អ** មិត្តដែលចេះដឹកនាំមិត្តឱ្យធ្វើល្អ ប្រៀបបីដូចជានាំមិត្តទៅជីកយកកំណប់ទ្រព្យដូច្នោះដែរ ។

គ-**មិត្ត ដែលចេះណែនាំមិត្តឱ្យបានស្តាប់នូវពាក្យដែលមិនធ្លាប់បានស្តាប់** ពាក្យដែលមិនធ្លាប់បានស្តាប់ក្នុងទីនេះ គឺសំដៅយកពាក្យដែលជាឱវាទល្អៗប្រាសចាកទោស ដូចជាព្រះធម៌ទេសនា ឬថាពាក្យទូន្មានរបស់គ្រូអាចារ្យឬចាស់ទុំណាដែលគាត់មានប្រក្រតី ពោលពាក្យដឹកនាំកូនចៅប្រុសស្រីឱ្យមានការយល់ត្រូវជាដើម ។

ឃ-**មិត្ត ដែលចេះប្រាប់ផ្លូវទៅកាន់ស្ថានសួគ៌ដល់មិត្ត** មានរឿងខ្លះមនុស្សយើង សូម្បីជាអ្នកឆ្លាតយ៉ាងណាក៏ដោយ ក៏មិនអាចដឹងរឿងរ៉ាវគ្រប់អន្លើបានឡើយ ដូចជានៅក្នុងដំណើរទៅកាន់ជាតិមុខជាដើម បើមិនអាស្រ័យនឹងព្រះធម៌របស់ព្រះមានព្រះភាគទេ រមែងមានការយល់ខុសជាធម្មតា ដូច្នេះការមានកល្យាណមិត្តដែលមានការចេះដឹងក្នុងរឿងនេះ គឺជាការប្រពៃណាស់។

## 4.មិត្តចេះមានចិត្តឈឺឆ្អាលមាន៤យ៉ាង

ក-**មិត្ត ដែលមិនត្រេកអរនៅពេលដែល**



**មិត្តមានសេចក្តីវិនាស** សេចក្តីវិនាសមាន៥យ៉ាង គឺ វិនាសញាតិ១ វិនាសទ្រព្យ១ វិនាសសុខភាព១ វិនាសសីល១ និងវិនាសទិដ្ឋិ១។ មិត្តប្រភេទនេះ តែងមានចិត្តករុណាអាណិតដល់មិត្ត នៅពេលមិត្តមានបញ្ហាដូចខាងលើ ព្រមទាំងជួយរកវិធីដោះស្រាយទៀតផង។

ខ-**មិត្ត ចេះត្រេកអរក្នុងពេលដែលមិត្តបាននូវការចម្រើនរុងរឿង** មិត្តប្រភេទនេះ តែងមានចិត្តមុទិតា គឺត្រេកអរតាម ដោយសេចក្តីថាមិនចេះច្រណែន ក្នុងការដែលមិត្តបាននូវលាភ ឬយសជាដើម ហើយមានតែការលើកស្ទួយការពារ

ថែមទៀត ។

គ-**មិត្ត ដែលចេះហាមឃាត់មនុស្សដែលនិយាយអាក្រក់អំពីមិត្ត** មិត្តប្រភេទនេះ តែងមានចិត្តឈឺឆ្អាលចំពោះមិត្ត ការពារកិត្តិយសមិត្ត បើមានអ្នកណានិយាយអាក្រក់អំពីមិត្ត តែងតែហាមឃាត់ភ្លាម គឺថាមិនមែនជាមនុស្សនិយាយចាក់បណ្តោយ ឬថាជាមនុស្សក្របីស៊ីក្នុងអូរដែលងាកទៅខាងណាក៏ត្រូវនោះឡើយ ។

ឃ-**មិត្ត ដែលចេះសរសើរនូវមនុស្សណាដែលនិយាយល្អអំពីមិត្ត ឬក៏អំពីគុណរបស់មិត្ត** មនុស្សយើងតែងមានចំណុចល្អ និងចំណុចអាក្រក់



ជាធម្មតា បើគេនិយាយអំពីចំណុចអាក្រក់របស់មិត្តត្រូវតែហាមឃាត់ តែបើគេនិយាយល្អអំពីមិត្តដែលមិត្តមានសេចក្តីល្អមែន ត្រូវតែសរសើរបន្ថែមដើម្បីបានសេចក្តីល្អ២យ៉ាងគឺ ម្យ៉ាងដើម្បីកំចាត់ចោលនូវការច្រណែន ក្នុងសេចក្តីល្អរបស់មិត្តម្យ៉ាងទៀត ដើម្បីឱ្យមិត្តកាន់តែប្រព្រឹត្តល្អឡើង ។

*4បើធ្វើខ្លួនជាឃ្មុំ មិនយូរប៉ុន្មានពិតជាបានជួបផ្កា*
*ដែលមានលំអងបរិបូណ៌ដោយក្លិន*
*មិនខានឡើយ ។*

សេពគប់បាបមិត្តពិតជានាំខ្លួន ឱ្យខុសផ្លូន១ជួនបានអាស្រូវ
គប់កល្យាណមិត្តពិតល្អពេកក្រូវ បានខុសឬត្រូវអាស្រ័យសេពគប់ ។

សាន~សុជា



## ៤.សមជីវិតា

ដោយច្រើន មនុស្សដែលចេះចាយវាយទ្រព្យបានល្អ ដឹងខ្ទង់ដែលត្រូវចំណាយ ក៏គឺជាមនុស្សដែលខុស្សាហ៍ ហើយខិតខំប្រឹងប្រែងរកទ្រព្យសម្បត្តិដោយកម្លាំងខ្លួនឯង ។

មនុស្សខ្លះ ចាយវាយខ្ជះខ្ជាយ មិនចេះសន្សំសំចៃសោះ ព្រោះទ្រព្យដែលខ្លួនបានមកនោះគឺបានដោយស្រួល១ពេក ដែលថាបានដោយស្រួលក្នុងទីនេះ គឺសំដៅទៅលើទ្រព្យដែលមិនមែនបានមកដោយកម្លាំងរបស់ខ្លួនឯង ។

កូនប្រុសស្រីដោយច្រើន ដែលមិនមាន

ការអប់រំល្អ មិនដែលក្លាយខ្លួនជាអ្នកគ្រប់គ្រងគ្រួសារ ហើយថែមទាំងមិនទាន់ចេះស្វែងរកទ្រព្យសម្បត្តិម្តងផង តែការចាយវាយរបស់គេហាក់ដូចជាមានលុយដាក់ធនាគារ រាប់កោដិអ៊ីចឹងឯង។ ពេលគេត្រូវការ គេអាងតែសុំពីឪពុកម្តាយរបស់គេ ដោយគេមិនបានដឹងទាល់តែសោះថា តើឪពុកម្តាយរបស់គេ មានការលំបាកយ៉ាងណាខ្លះ ទម្រាំតែបានទ្រព្យសម្បត្តិនោះមក ជួនកាលគ្រាន់តែចង់ទៅដើរលេងជាមួយមិត្តភក្តិ ក៏ហ៊ានហាមាត់សុំលុយពីម៉ែឪដែរ ដូចជាមិនចេះអៀនមាត់ទាល់តែសោះ។ គ្រាខ្លះ កាលបើឪពុកម្តាយមិនបានឱ្យគ្រប់



ចំនួនដែលគេត្រូវការ គេក៏សំដែងនូវអាកប្ប-កិរិយាមិនពេញចិត្ត ធ្វើឫកពាមិនគួរឱ្យស្រឡាញ់ទាល់តែសោះ *កូនរបៀបនេះ ពិតជារំខានមែន*។

អ្នកលេងល្បែងស៊ីសងដោយច្រើន ក៏ចាយវាយមិនសូវចេះគិតដែរ ព្រោះគេគិតថា *"ឱ្យតែអញលេងភ្នាល់ទៀតគង់តែឈ្នះមិនខាន"*។

អ្នកមានមិត្តភក្តិ ឬបងប្អូននៅបរទេសមួយចំនួនក៏ដូចគ្នាដែរ ការងារធ្លាប់ធ្វើខ្លួនឯងកើតក៏ស្រាប់តែលែងចេះធ្វើ ហ៊ានយកលុយដែលមិត្តភក្តិ ឬបងប្អូនផ្ញើមកនោះ ទៅជួលអ្នកបំរើឱ្យធ្វើជំនួសវិញ ឬក៏ចំណាយក្នុងរឿងមិនបានការផ្សេងៗ

ទៀត ដោយគិតអាងថា "ឱ្យតែខ្វះលុយ អញនឹងសុំគេទៀត"។ ត្រូវចាំភាសិតមួយថា *"អ្នកសុំរមែងទាស់ចិត្តអ្នកឱ្យ ការសុំនោះហើយនាំឱ្យបែកមិត្ត អ្នកសុំគ្មាននរណាចង់ដើរជិត ជាតិជាបណ្ឌិតត្រូវគិតហើយចាំសុំ"*។

ចំពោះលោកអ្នក ដែលមានមិត្តភក្តិ ឬបងប្អូននៅបរទេសដែរ តែបើមិនមានគំនិតដូចបុគ្គលខាងលើនេះទេ សូមកុំទាន់អាលខឹងអ្នកសរសេរធ្វើអ្វី គ្រាន់តែតាំងចិត្តថា "អញនឹងមិនធ្វើដូចគេ" ប៉ុណ្ណេះទៅ ជាការប្រពៃណាស់ទៅហើយ។

តាមពិតទ្រព្យដែលអ្នកដទៃ មានសន្តាន



ចិត្តជួយផ្តល់ឱ្យមក មិនមែនថាមិនឱ្យទទួលនោះទេ បើមានការចាំបាច់ហើយគប្បីតែទទួលទៅចុះ ប៉ុន្តែត្រូវចេះដឹងប្រមាណក្នុងការទទួលផង កាលបើទទួលយកហើយ រឹតតែត្រូវចំណាយឱ្យបានល្អជាងទ្រព្យ ដែលយើងរកបានដោយខ្លួនឯងទៅទៀត ព្រោះទ្រព្យដែលយើងរកបានដោយខ្លួនឯង បើយើងប្រមាទក្នុងការចាយខ្លះ ក៏មិនសូវមានអ្នកតិះដៀលដែរ តែទ្រព្យដែលគេផ្តល់ឱ្យមក បើចាត់ចែងមិនបានល្អទេ ម្ចាស់ទ្រព្យគេនឹងអាចពោលតិះដៀលយើងថា *"ជាមនុស្សធ្ងន់ ខំលើកយ៉ាងណាក៏មិនរួចដែរ"*។

## ហេតុគួរចាយទ្រព្យ៤យ៉ាង[១]

ទ្រព្យសម្បត្តិរកបានមកហើយ មិនមែនថាមិនត្រូវអស់ទៅវិញនោះទេ ប៉ុន្តែគួរតែឱ្យអស់ក្នុងហេតុដែលគួរអស់។ ព្រះពុទ្ធសាសនាបានបង្រៀនឱ្យមនុស្សចេះបែងចែកទ្រព្យជា៤ ចំណែកក្នុងការចំណាយគឺ

១/ចិញ្ចឹមជីវិតខ្លួនឯង មាតាបិតា បុត្រភរិយា ឬទាសកម្មករដែលនៅជាមួយខ្លួន។

២/ចាយទ្រព្យដើម្បីការពារទ្រព្យ គឺចាយដោយការវៃឆ្លាត ដើម្បីដោះខ្លួនឯងឱ្យរួចពីសេចក្តីអន្តរាយផ្សេងៗ ដូចជាអន្តរាយព្រោះភ្លើង

១-អង្គុត្តរ- ចតុក្កនិ- បត្តកម្មវគ្គ បិដកលេខ៤២ ចាប់ពីទំព័រ១៦៦ តទៅ។



ព្រោះទឹក ឬក៏អន្តរាយព្រោះចោរជាដើម។

៣/ចាត់ចែង សម្រាប់ជួយសង្គ្រោះញាតិ និងទុកសម្រាប់ទទួលភ្ញៀវ ដែលមកពីចម្ងាយ.... (សំដៅដល់ពលី៥យ៉ាង មានញាតិពលីជាដើម)។

៤/ចាត់ចែងបរិច្ចាគធ្វើទាន ដល់សមណ-ព្រាហ្មណ៍ អ្នកមានសីលជាទីស្រឡាញ់។

ការអស់ទៅនៃទ្រព្យសម្បត្តិ តាមវិធីដែលរៀបរាប់មកនេះ ឈ្មោះថាអស់ទៅដោយប្រពៃ មិនគួរឱ្យសោកស្តាយឡើយ តែដែលអស់ទៅហើយ ថែមទាំងគួរឱ្យរង្កៀសនោះ គឺសំដៅយកការចំណាយប្រាក់ ក្នុងរឿងអបាយមុខផ្សេងៗ

ដូចជា

-ចំណាយក្នុងការដើរលេងស្រី

-ចំណាយក្នុងការផឹកទឹកស្រវឹង និងសេពគ្រឿងញៀនផ្សេងៗ

-ចំណាយក្នុងការសប្បាយបរិភោគ ក្នុងភាពជាអ្នកលេងស៊ី

-ចំណាយក្នុងការលេងល្បែងស៊ីសង

-ចំណាយក្នុងការ ដើរលេងតាមច្រកល្ហករឿយៗនៅពេលយប់ព្រលប់

-ចំណាយក្នុងការដើរមើលមហោស្រព ឬល្បែងច្រៀងរាំរឿយៗ



-ប្រកបរឿយៗ នូវការខ្ជិលច្រអូស

-សេពគប់បាបមិត្ត។

សេចក្ដីដូចបានរៀបរាប់មក ខាងលើនេះសុទ្ធតែជាអបាយមុខទាំងអស់ បូរាណពោលថា *"អបាយមុខ ជង្រុកហិន"* ដូច្នេះត្រូវតែជៀសវាងឱ្យឆ្ងាយ បើមិនដូច្នោះទេ ពិតជាបង់ទាំងទ្រព្យអភ័ព្វទាំងបុណ្យ និងធ្ងន់ដោយបាបមិនខាន។

ជីវិតរបស់យើងម្នាក់ៗ មានតំលៃណាស់សម្រាប់រង្វង់ក្រុមគ្រួសារ។ ស្វាមីភរិយា តែងត្រូវការភាពស្មោះត្រង់រវាងគ្នានិងគ្នា កូនប្រុសស្រីតែងត្រូវការភាពកក់ក្ដៅពីឪពុកម្ដាយ ចំណែក

ឪពុកម្តាយ ក៏ត្រូវការនូវភាពឱនលំទោននិងការស្តាប់បង្គាប់ពីកូនវិញដែរ។ ដូច្នេះ បើសមាជិកនីមួយៗនៃក្រុមគ្រួសារណា មិនយកទ្រព្យសម្បត្តិទៅចំណាយក្នុងរឿងអបាយមុខផ្សេងៗទេ ក្រុមគ្រួសារនោះ ពិតជាមានសុភមង្គល មិនមានការទាស់ទែងខ្វែងគំនិតគ្នាឡើយ។

ការចិញ្ចឹមជីវិតស្មើនេះ សំដៅដល់ការដឹងប្រមាណក្នុងការចាយវាយទ្រព្យសម្បត្តិ មិនខ្ជះខ្ជាយ ឬថាមិនហ៊ឺហាតាមសម័យ គឺចេះសម្លឹងមើលកាលជាអនាគត ព្រោះមនុស្សគ្រប់គ្នាដែលកើតមកពេញលក្ខណៈជាមនុស្ស បើមិនស្លាប់ពី



ក្មេងទេ គង់តែនឹងក្លាយទៅជាអ្នកគ្រប់គ្រងក្រុមគ្រួសារមួយមិនខាន ហើយអ្នកដែលអាចគ្រប់គ្រងក្រុមគ្រួសារបានល្អ មិនមែនជាមនុស្សខ្ជះខ្ជាយ ឬថា ជាមនុស្សគ្មានគំនិតនោះឡើយ។

*4ការចេះចាយវាយទ្រព្យសម្បត្តិទៅតាម*
*គន្លងធម៌គឺជាពរដ៏ប្រសើរ*
*សម្រាប់ឃរាវាស*
*គ្រប់គ្នា។*

ចាយវាយគួរលៃតាមកម្លាំងទ្រព្យ លើសហួសមិនគាប់ពីភ័ព្វខ្លួនមាន
កុំភ្លាំងភ្លេចខ្លួនក្រែងអន្តរធាន កុំក្លាបំពានបណ្តាំមេជី ។

សាន~សុជា



## និដ្ឋធម្មិកត្ថប្រយោជន៍ ជាប្រយោជន៍ថ្នាក់ក្រោម

សម្បទា៤យ៉ាង ដែលបានរៀបរាប់មកហើយនេះ គឺជាកិច្ចដែលត្រូវប្រកបដើម្បីឱ្យកើតប្រយោជន៏សុខក្នុងពេលបច្ចុប្បន្ន គឺក្នុងអត្តភាពនេះឯង ចាត់ជាប្រយោជន៏ថ្នាក់ក្រោមដែលជាគ្រឹះដើម្បីជាឈ្នាន់ សម្រាប់ឈោងចាប់នូវប្រយោជន៏ថ្នាក់លើជាបន្តទៀត ។

បើគ្រាន់តែប្រយោជន៏ថ្នាក់ក្រោម បំពេញមិនបានល្អហើយ តើនឹងមានសមត្ថភាពអ្វីដើម្បីនឹងចាប់យកនូវប្រយោជន៏ថ្នាក់លើទៀតបាន!

ដូច្នេះ សូមកុំមានគំនិតមាក់ងាយនូវប្រយោជន៍ថ្នាក់ក្រោមនេះឱ្យសោះ ព្រោះជាការសំដែងឡើងរបស់ព្រះសម្មាសម្ពុទ្ធ។

សូមមនុស្សគ្រប់គ្នា បានស្គាល់នូវប្រយោ-ជន៍តាមប្រការដូចដែលរៀបរាប់មកហើយ និងចូរប្រព្រឹត្តតាម ដើម្បីឱ្យបានសេចក្តីសុខសមតាមប្រាថ្នាចុះ។

ឥឡូវនេះ នឹងរៀបរាប់អំពីប្រយោជន៍ថ្នាក់កណ្តាល គឺប្រយោជន៍សម្រាប់ជីវិតទៅក្នុងជាតិខាងមុខ ដែលហៅថា *"សម្បរាយិកត្ថ-ប្រយោជន៍"* ជាបន្តទៀត។



## II.សម្បរាយិកត្ថប្រយោជន៍

*ប្រយោជន៍ក្នុងបរលោក*

ប្រយោជន៍ដែលបុគ្គលគួរបំពេញ ដើម្បីជាបុញ្ញនិធិ គឺកំណប់បុណ្យទៅក្នុងលោកខាងមុខ ហៅថា *"សម្បរាយិកត្ថៈ"* គឺជាប្រយោជន៍សម្រាប់ជីវិតតទៅក្នុងភពខាងមុខ។

សព្វថ្ងៃនេះ មនុស្សយើងមានអាយុក្ខ័យចុះមកសល់ត្រឹមតែ៧៥ឆ្នាំប៉ុណ្ណោះ បើមានបុណ្យច្រើនក៏អាចរស់នៅបានយូរជាងនោះ បន្តិចបន្តួចប៉ុណ្ណោះ ប៉ុន្តែក៏មិនប្រាកដថា សុទ្ធតែបានគ្រប់អាយុក្ខ័យទើបស្លាប់នោះទេ ខ្លះស្លាប់តាំងតែពីនៅក្នុងផ្ទៃម្តាយម្ល៉េះ ខ្លះប្រសូតិចាកគភ៌ភ្លាមស្លាប់ក៏មាន ខ្លះទៀតក៏ស្លាប់

ក្នុងបឋមវ័យ ខ្លះក៏ស្លាប់ក្នុងវ័យកណ្ដាល ខ្លះទៀតក៏ស្លាប់ក្នុងវ័យចាស់ ហើយបើទុកជាស្លាប់ក្នុងវ័យណាក៏ដោយ គឺស្លាប់ទាល់តែអស់ដោយឥតមានសេសសល់ម្នាក់ឡើយ។

កាលបើស្លាប់ហើយ បើពូជនៅមាន ក៏ត្រូវតែដុះជាបន្តទៀតជាដាច់ខាត។ ពូជគឺកម្មដែលធ្វើក្នុងជាតិនេះឬក្នុងអតីតជាតិ ការដុះបន្តគឺសំដៅដល់ការបដិសន្ធិនៅក្នុងភពថ្មី (គឺកើតជាកំណើតថ្មីមួយទៀតបន្ទាប់ពីស្លាប់ភ្លាម) ដោយអំណាចកម្មដែលបានធ្វើហើយនោះឯងជាបច្ច័យ វៀរលែងតែព្រះអរហន្ត។

កម្មល្អ តែងឱ្យបដិសន្ធិក្នុងសុគតិភព គឺមនុស្សនិងទេវតា ចំណែកខាងកម្មអាក្រក់ តែងឱ្យបដិសន្ធិក្នុង



អបាយភូមិ ៤ គឺ នរក ប្រេត តិរច្ឆាន និងអសុរកាយ។

ដូច្នេះ បញ្ហាជាតិមុខសម្រាប់យើងម្នាក់ៗមិនមែនជារឿងលេងសើចនោះទេ កុំរៀននាំគ្នានិយាយថា *"ពេលស្លាប់លែងដឹងខ្លួនទៅហើយ កើតទៅជាអ្វីក៏ដោយឱ្យតែមានញីឈ្មោល"*។ ដូចជាប្រថុយប្រថានពេកទេដឹង ?

ដែលគេនិយាយថា *"ឱ្យតែមានញីឈ្មោល"* នោះ គេសំដៅត្រឹមតែកំណើតសត្វតិរច្ឆានប៉ុណ្ណោះ គេមិនបានដឹងថា មានកំណើតដែលលំបាកជាងសត្វតិរច្ឆាន ដូចជានរកជាដើមនោះទេ។

តាមពិត ការកើតជាសត្វតិរច្ឆាន បើទុកជាត្រូវគេថ្នាក់ថ្នមចិញ្ចឹមយ៉ាងណាក៏ដោយ ក៏គ្មានបាន

ប្រយោជន៍អ្វីសម្រាប់ខ្លួនឯងដែរ បានត្រឹមតែលំអភ្នែកគេតែប៉ុណ្ណោះ ម្យ៉ាងទៀត មិនអាចប្រព្រឹត្តនូវទាន សីល ឬស្តាប់ធម៌ដើម្បីអប់រំជីវិតបានឡើយ ។

ការភ្លាត់ជើងដួល មិនសូវគ្រោះថ្នាក់ប៉ុន្មានទេ ហើយថែមទាំងអាចក្រោកឡើងបានយ៉ាងស្រួល ប៉ុន្តែបើភ្លាត់ធ្លាក់ទៅក្នុងអបាយភូមិហើយ សេចក្តីទុក្ខមិនអាចគណនាបានឡើយ ហើយមិនងាយក្នុងការងើបឡើងមកវិញបានទេ ។

មនុស្សយើងគ្រប់គ្នា មិនមានស្រឡាញ់អ្វីឱ្យខ្លាំងជាងស្រឡាញ់ខ្លួននោះឡើយ ម្នាក់ៗខិតខំស្វែងរកអាហារបរិភោគដើម្បីរស់ ហើយមនុស្សដែលឆ្លាតគេមិនមែនហ៊ឺហាសប្បាយចាយវាយតែមួយថ្ងៃឱ្យទាល់



តែអស់ទ្រព្យដែលរកបានមកនោះទេ គេពិតជារំលែកខ្លះទុកសម្រាប់ថ្ងៃក្រោយមិនខានឡើយ ព្រោះថាបើគេមិនលៃលកដូច្នេះទេ ថ្ងៃក្រោយគេនឹងក្លាយជាមនុស្សកំសត់ លែងមានអ្វីបរិភោគដូចថ្ងៃនេះទៀតហើយ ដូចគ្នានេះដែរអ្នកមានប្រាជ្ញាក៏គិតជីវិតជាតិមុខមិនខុសអំពីការដែលគេគិតជីវិតថ្ងៃស្អែកនោះឡើយ ។

ដូច្នេះ មនុស្សយើងមិនអាចដំអក់នៅតែក្នុងប្រយោជន៍បច្ចុប្បន្ន ដែលជាឈ្នាន់ថ្នាក់ក្រោមប៉ុណ្ណោះទេ គឺត្រូវតែកសាងប្រយោជន៍បរលោកថែមទៀតទើបប្រពៃ ព្រោះយើងមិនមែនរស់នៅតែជាមួយនឹងជីវិតបច្ចុប្បន្ននេះឯណា មិនយូរប៉ុន្មានទៀតទេនឹងត្រូវស្លាប់អស់ទៅហើយ ម្យ៉ាងទៀតបើតណ្ហានៅមាន

មុខជានឹងមានជាតិថ្មីក្នុងលោកខាងមុខៗ ទៀតមិនខាន ហើយអ្វីដែលជាដើមទុនសម្រាប់ជាតិថ្មីនោះ មានតែបុណ្យកុសលប៉ុណ្ណោះ ។

*ពាក្យថាបុណ្យកុសលដែលត្រូវធ្វើ និងពាក្យថាប្រយោជន៍ក្នុងបរលោកនេះ មានន័យដូចគ្នា គ្រាន់តែផ្សេងដោយព្យញ្ជនៈប៉ុណ្ណោះ ។*

ព្រះសម្ពុទ្ធទ្រង់ត្រាស់នឹង ទីឃជាណុមាណព អំពីប្រយោជន៍ក្នុងបរលោក មាន៤ប្រការគឺ[១]

**១-សទ្ធាសម្បទា** ដល់ព្រមដោយសទ្ធា ។

**២-សីលសម្បទា** ដល់ព្រមដោយសីល ។

**៣-ចាគសម្បទា** ដល់ព្រមដោយការបរិច្ចាគទាន ។

---

១-អង្គុត្តរនិ- អដ្ឋកនិ- សទ្ធានវគ្គ បិដកលេខ៤៨ ចាប់ពីទំព័រ២៤៩ តទៅ ។



**៤-បញ្ញាសម្បទា** ដល់ព្រមដោយបញ្ញា ។

## ១-សទ្ធាសម្បទា

*ដល់ព្រមដោយសទ្ធា ។*

ការជឿចំពោះបុគ្គល ឬវត្ថុទៅតាមតែការដឹងការឮមិនជាក់ច្បាស់ ហើយចេះតែជឿដោយការចូលចិត្តស៊ប់( អធិមោក្ខៈ) ដែលមិនមានហេតុផលគួរជឿបាន លោកមិនហៅថា "សទ្ធា" ឡើយ ព្រោះថា "សទ្ធា"នេះ ជាគុណជាតិល្អ កើតតែនៅក្នុងចិត្តល្អដែលជាសោភណចិត្តប៉ុណ្ណោះ មិនដែលកើតជាមួយនឹងអកុសលចិត្តទេ ។

គប្បីស្គាល់នូវសទ្ធា ដោយអាការៈដូច្នេះគឺ

-*កម្មសទ្ធា* ការជឿទៅលើកម្ម គឺជឿថា "**បាបកម្ម** ជាអំពើញ៉ាំងសត្វលោកឱ្យថោកទាប **កុសលកម្ម** ជាអំពើញ៉ាំងសត្វលោកឱ្យប្រសើរថ្លៃថ្នូរ........"។

-*វិបាកសទ្ធា* ការជឿទៅលើផល គឺជឿថា "**សេចក្តីវិនាសហិនហោច និងសេចក្តីទុក្ខគ្រប់ប្រការ** ដែលខ្លួនត្រូវជួបប្រទះ គឺជាផលរបស់កម្មអាក្រក់ដែលខ្លួនធ្លាប់បានធ្វើហើយ **ចំណែកសេចក្តីសុខចម្រើន**ដែលខ្លួនត្រូវទទួលបាន គឺជាផលរបស់កម្មល្អដែលខ្លួនធ្លាប់ធ្វើ ដោយមិនមានអ្នកណាជាអ្នកធ្វើជំនួសនោះទេ"។

-*កម្មស្សកតាសទ្ធា* ជឿថា "**សត្វទាំងឡាយមានកម្មជារបស់ខ្លួន** គឺថាកម្មដែលសត្វលោកបានធ្វើហើយ ទោះបីជាល្អក្តី អាក្រក់ក្តី តែងតែជាប់ទៅតាម



សត្វលោកនោះជានិច្ច ដូចជាកង់រទេះដែលវិលទៅតាមជើងគោ ឬដូចជាស្រមោលអន្ទោលតាមប្រាណ បើទុកជាខំរត់គេច ឬរាយមន្តការពារយ៉ាងណា ក៏មិនអាចរួចផុតអំពីអំណាចកម្មបានឡើយ"។

-***តថាគតពោធិសទ្ធា*** ជឿការត្រាស់ដឹងរបស់ព្រះតថាគត គឺជឿថា "ព្រះមានព្រះភាគនោះ ព្រះអង្គជាអរហន្ត ជាសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ មានព្រះដំណើរល្អ ជ្រាបច្បាស់នូវលោក ឥតមានបុគ្គលដទៃស្មើ ទូន្មាននូវបុរសដែលគួរទូន្មានបាន ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ដឹងនូវចតុរារិយ-សច្ច លែងវិលត្រឡប់មកកាន់ភពថ្មីទៀត" មួយអន្លើដោយការជឿគុណព្រះធម៌ និងគុណព្រះសង្ឃផង។

ការជឿដែលចាត់ចូលក្នុង សទ្ធាសម្បទានេះ គឺសំដៅដល់ការជឿក្នុងរឿងដែលមានហេតុផល ស្រប ទៅតាមធម្មជាតិដែលមានពិតៗ មិនមែនជារឿង ភ្ញាក់ផ្អើលនោះឡើយ ។

ការគោរពជឿវត្ថុស័ក្តិសិទ្ធិដទៃៗ ក្រៅអំពី ប្រការដែលរៀបរាប់មកខាងលើ មិនមែនជាសទ្ធាដែល គួរបណ្តុះនោះទេ ហើយបើកំពុងតែមានក្នុងចិត្តគំនិត គួរតែប្រញាប់លះបង់ចោលទើបប្រពៃ ព្រោះការជឿ នោះ នាំឱ្យខាតបង់ទាំងពេលវេលា វិនាសទាំងសម្មាទិដ្ឋិ និងជាឧបនិស្ស័យនៃមិច្ឆាទិដ្ឋិតទៅទៀតផង ។

បរិស័ទរបស់ព្រះសម្មាសម្ពុទ្ធ ត្រូវតែជាអ្នក មានហេតុផល មិនមែនចេះតែភ្ញាក់ផ្អើលតាមតែគេ



ចាក់ ដូចជាគោដែលមិនធ្លាប់ចូលនឹមនោះទេ ។

## វិបត្តិរបស់ឧបាសកឧបាសិកា៥យ៉ាង[(១)]

**ក-អស្សទ្ធោ ហោតិ** ជាអ្នកមិនមាន សទ្ធា ។

**ខ-ទុស្សីលោ ហោតិ** ជាអ្នកទ្រុស្តសីល ។

**គ-កោតុហលមង្គលិកោ ហោតិ** ជា អ្នកប្រកាន់មង្គលភ្ញាក់ផ្អើល ។

**ឃ-មង្គលំ បច្ចេតិ នោ កម្មំ** ជាអ្នក ជឿតែមង្គល មិនជឿកម្ម ។

**ង-ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វការំ ករោតិ** ជាអ្នក

---

១-អង្គុត្តរនិ- បញ្ចកនិ- ឧបាសកវគ្គ បិដកលេខ៤៥ ចាប់ពីទំព័រ១៥៥ ទៅ ។

ស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅព្រះពុទ្ធសាសនា ហើយធ្វើបុណ្យនឹងទក្ខិណេយ្យបុគ្គលនោះ ។

ព្រះអង្គទ្រង់ត្រាស់ហៅ នូវឧបាសកដែលជាអ្នកប្រកបដោយធម៌៥យ៉ាងខាងលើថា ជា**ចណ្ឌាល-ឧបាសក** (ឧបាសកអាក្រក់) ផង ជា**មលឧបាសក** (ឧបាសកមានមន្ទិល) ផង ជា**បដិកិដ្ឋឧបាសក** (ឧបាសកគួរស្អប់) ផង ។

## សម្បត្តិរបស់ឧបាសកឧបាសិកា៥យ៉ាង[(១)]

**ក-សទ្ធោ ហោតិ** ជាអ្នកមានសទ្ធា ។

**ខ-សីលវា ហោតិ** ជាអ្នកមានសីល ។

**គ-អកោតូហលមង្គលិកោ ហោតិ**

១-អង្គុត្តរនិ- បញ្ចកនិ- ឧបាសកវគ្គ បិដកលេខ៤៥ ចាប់ពីទំព័រ១៥៦ ទៅ ។



ជាអ្នកមិនប្រកាន់មង្គលភ្ញាក់ផ្អើល ។

**ឃ-កម្មំ បច្ចេតិ នោ មង្គលំ** ជាអ្នកជឿតែកម្ម មិនជឿមង្គល ។

**ង-ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ** ជាអ្នកមិនស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅពុទ្ធសាសនា ធ្វើបុណ្យតែក្នុងពុទ្ធសាសនានេះ ។

ព្រះអង្គទ្រង់ត្រាស់ហៅ នូវឧបាសកដែលជាអ្នកប្រកបដោយធម៌៥យ៉ាងខាងលើថា **រតនឧបាសក** (ឧបាសកកែវ) ផង ថា**បទុមឧបាសក** (ឧបាសក-ផ្កាឈូកក្រហម) ផង ថា**បុណ្ឌរិកឧបាសក** (ឧបាសក-ផ្កាឈូកស) ផង ។

សូមពុទ្ធបរិស័ទ មានជំនឿតែក្នុងរឿងណា ដែលមានហេតុផល និងខំប្រព្រឹត្តប្រតិបត្តិឱ្យបានជាពុទ្ធបរិស័ទល្អ សូមកុំឱ្យមានឈ្មោះថា ***"ចណ្ឌាល-ឧបាសក"*** ជាដើមនោះឡើយ ។

| | |
|---|---|
| សាសនាគឺជាមាគ៌ាជីវិត | ច្នេះត្រូវគួរគិតពិនិត្យហេតុការណ៍ |
| មុនកាន់មុនជឿគួរពិចារណា | ជឿតែរឿងណាដែលមានហេតុផល ។ |

សាន-សុជា



## ២-សីលសម្បទា

*<u>ដល់ព្រមដោយការរក្សាសីល ។</u>*

ពាក្យថា **"សីល"** បានដល់វិធីសម្រាប់សិក្សាហាត់ទូន្មាននូវកាយនិងវាចា ឱ្យមានរបៀបរៀបរយល្អ ឬថា ជាធម៌ប្រតិបត្តិដើម្បីការពារនូវទោសមិនឱ្យកើតឡើងតាមផ្លូវកាយ និងផ្លូវវាចា ។

***សីល*** ដែលចាត់ចូលក្នុងសីលសម្បទា[១] នេះ សំដៅយកនិច្ចសីលដែលមានសិក្ខាបទ៥គឺ

***ក-មិនសម្លាប់សត្វ*** ការមិនសម្លាប់សត្វគឺជាការអនុគ្រោះដល់សត្វលោកទាំងអស់ ឱ្យបានរស់នៅរហូតអស់អាយុកាល ដោយមិនមានការភ័យខ្លាចតក់ស្លុត ។

---

១-អង្គុត្តរនិ- អដ្ឋកនិ- សទ្ធានវគ្គ បិដកលេខ៤៨ ទំព័រ២៥០ ។

សត្វលោកទាំងអស់ មានអធ្យាស្រ័យមិនដូចគ្នាទេ តែដូចគ្នាមួយចំណុច គឺត្រង់ដែលចង់បានសេចក្តីសុខហើយភ័យខ្លាចសេចក្តីទុក្ខ។ កាលបានពិចារណាយ៉ាងនេះរឿយៗហើយ ប្រាជ្ញាស្មារតីក៏កើតឡើងយល់ច្បាស់ថា ការសម្លាប់សត្វជាអំពើគួរឱ្យរង្កៀសយ៉ាងក្រៃលែងមិនគួរប្រព្រឹត្តទាល់តែសោះ ព្រោះសត្វលោកទាំងអស់សុទ្ធតែចង់រស់នៅដោយសុខសាន្ត ដូចជាយើងអ៊ីចឹងដែរ។

ការសម្លាប់ចាប់ចងទាំងអស់ គឺកើតឡើងអំពីបុគ្គលដែលអត់សីលទី១នេះឯង ដូច្នេះគួរបានពិចារណានូវគុណរបស់អ្នកមានសីល ដែលអ្នកមានសីលទាំងអស់ សូម្បីច្រើនគ្នាយ៉ាងណាក៏ដោយ ក៏មិនដែល



បៀតបៀនសត្វលោកណាមួយ ឱ្យដល់នូវសេចក្តីទុក្ខឡើយ ហើយមិនត្រឹមតែមិនសម្លាប់មិនបៀតបៀនប៉ុណ្ណោះទេ ថែមទាំងមានមេត្តាករុណាដល់សត្វលោកទៀតផង ទើបបានជាការបូជាដល់អ្នកមានសីលរមែងមានផលច្រើន នេះនិយាយចំពោះអ្នកមានសីលពិតប្រាកដ មិនមែនគ្រាន់តែយកផ្លាកសីលមកពាក់ដោយមិនប្រតិបត្តិតាមនោះទេ។

ការមិនសម្លាប់សត្វ គឺជាការអនុគ្រោះខ្លួនឯងផង អនុគ្រោះសត្វដទៃផងឱ្យមានសេចក្តីសុខទាំងសងខាង និងជាការដាំពូជសេចក្តីសុខនិងពូជអាយុវែងតទៅជាតិខាងមុខផង។

*ភ័យតែងកើតមានអំពីអ្នកអត់សីល។*

*ខ-មិនលួចទ្រព្យអ្នកដទៃ* អ្នកដែលលួចទ្រព្យគេមានឈ្មោះថា *"ចោរ"* មកពីមានចោរហ្នឹងហើយទើបមានប៉ូលីស ប្រទេសជាតិត្រូវចំណាយលុយមិនស្មើរទេដើម្បីបង្កើតប៉ូលីស ដូច្នេះអ្នកធ្វើចោរឈ្មោះថា បំផ្លាញខ្លួនឯងផង បំផ្លាញអ្នកដទៃផង និងជារោគនៃសង្គមទាំងមូលផង។

ការលួចទ្រព្យគេ បើទុកជាប៉ូលីសចាប់មិនបានក៏ដោយ ក៏ត្រូវខ្លួនឯងចាប់បានដែរ ព្រោះគេចទៅទីណាក៏មិនអាចរត់គេចពីខ្លួនឯងបានឡើយ។

ប៉ូលីសចាប់បាន គេយកទៅដាក់មន្ទីរឃុំឃាំងមានកាលកំណត់មិនយូរប៉ុន្មានឡើយ ហើយថែមទាំងមានបាយបរិភោគទៀតផង តែបើខ្លួនឯងចាប់ខ្លួនឯង



បានហើយ គឺរមែងតែងតែបោះខ្លួនឯងចូលទៅក្នុងអបាយភូមិមាននរកជាដើម មានសេចក្តីទុក្ខជាអនេកព្រោះចោរកម្មដែលធ្លាប់ធ្វើហើយ បានចូលមកកាត់ក្តីឱ្យនៅពេលទៀបនឹងស្លាប់។

ការមិនលួចទ្រព្យអ្នកដទៃ គឺជាការអនុញ្ញាតឱ្យអ្នកដទៃរីករាយនឹងទ្រព្យរបស់គេ ដូចគ្នានឹងការដែលយើងស្រឡាញ់ទ្រព្យរបស់យើងដែរ ហើយជាការសន្សំពូជមានបាន និងពូជគង់វង្សទ្រព្យសម្បត្តិទៅជាតិខាងមុខទៀត។

*អ្នកមានសីលមិនធ្វើចោរទេ មានតែអ្នកអត់សីល ឬថាអ្នកដែលពាក់ផ្លាកសីលក្លែងក្លាយប៉ុណ្ណោះដែលហ៊ានធ្វើអំពើបែបនេះ។*

*គ-មិនប្រព្រឹត្តខុសក្នុងកាម* ការមិនប្រព្រឹត្តអនាចារក្នុងរឿងកាមគុណ គឺការមិនប្រព្រឹត្តខុសសីលធម៌លើកូនប្រពន្ធអ្នកដទៃ និងមិនប្រព្រឹត្តក្បត់ចិត្តភរិយាឬស្វាមីរបស់ខ្លួន។

សត្វតិរច្ឆានដោយច្រើន មិនមានធម្មសញ្ញាគឺការពិចារណារឿងខុសត្រូវទេ តែកាមសញ្ញារបស់សត្វទាំងអស់នោះ អាចថាមានកាលមានរដូវច្បាស់លាស់គ្រាន់បើដែរ ចំណែកភាពជាមនុស្សបើមិនកាន់សីលទី៣នេះទេ ពិតជាលំបាកនឹងប្រៀបផ្ទឹមជាមួយនឹងសត្វតិរច្ឆានដោយពិត។

ក្នុងពិភពលោក គេចំណាយលុយមិនតិចទេ ដើម្បីព្យាបាលជំងឺកាមរោគ ជាពិសេសគឺជំងឺសម័យថ្មី



ដែលហៅថា "**អេដស៍**" ។

អ្នកដែលប្រព្រឹត្តខុស ក្នុងសិក្ខាបទទី៣នេះ គឺជាភ្នាក់ងារចម្លងមេរោគអេដស៍យ៉ាងគួរឱ្យខ្លាច។

មនុស្សយើងគួរតែហ្វឹកហាត់ចិត្ត ឱ្យមានសេចក្តីសន្តោសក្នុងរឿងកាមគុណ គឺឱ្យចេះត្រេកអរតែនឹងប្តីឬប្រពន្ធរបស់ខ្លួនប៉ុណ្ណោះ ដោយមិនបណ្តែតបណ្តោយតាមតែចំណង់ បើមិនដូច្នោះទេ សូម្បីគេលើកពិភពលោកនេះឱ្យទាំងមូលក៏មិនគ្រប់គ្រាន់ដែរ។

ពាក្យថា "*គ្រប់គ្រាន់ដោយការប្រាថ្នា*" នោះមិនមានសោះឡើយ គឺប្រាថ្នាច្រើនឡើង ការខ្វះខាតក៏កាន់តែច្រើនឡើងដែរ តែ "*ការមិនប្រាថ្នា*" ប៉ុណ្ណោះទើបជាការគ្រប់គ្រាន់។

ការសមាទានសិក្ខាបទទី៣នេះ នាំឱ្យគ្រួសារអ្នកដទៃសុខសាន្តផង នាំឱ្យមានភាពសុខសប្បាយនិងទុកចិត្តគ្នាក្នុងរង្វង់ក្រុមគ្រួសាររបស់ខ្លួនឯងផង និងជាការដាំពូជសុខសប្បាយទៅក្នុងជាតិខាងមុខផង ។

***ឃ-មិននិយាយកុហក*** ការមិននិយាយកុហកគឺជាការឱ្យនូវភាពពិតត្រង់ដល់អ្នកដទៃ ដោយមិនឱ្យអ្នកដទៃភ័ន្តច្រឡំ ដូចគ្នានឹងការដែលយើងចង់ឱ្យអ្នកដទៃពោលពាក្យពិតត្រង់ចំពោះយើងដែរ ។

ការនិយាយស្តី អាចធ្វើឱ្យមនុស្សយើងថ្លៃថ្នូរ ឬថោកទាបបាន ។

ការនិយាយពាក្យពិត ធ្វើឱ្យខ្លួនឯងជាមនុស្សមានខ្លឹម តែការពោលកុហកវិញដូចជាដើមឈើដែលប្រហោងក្នុង ។



អ្នកពោលពាក្យពិត រមែងមានអ្នកជឿស្តាប់ទាំងក្នុងលោកនេះនិងក្នុងលោកខាងមុខ ។

***ង-មិនផឹកទឹកស្រវឹង*** ទឹកស្រវឹងគឺជាគ្រឿងខ្ចាស់ទៅនឹងសតិស្មារតី ។ មនុស្សដែលបាត់បង់ស្មារតីធ្វើអ្វីៗមិនបានល្អឡើយ ។

មនុស្សយើងគ្រប់គ្នាដែលកើតមក មានការខ្វះខាតនូវសតិស្មារតីស្រាប់ទៅហើយ បើផឹកទឹកស្រវឹងបន្ថែមទៀត គឺជាការបន្ថយនូវកម្លាំងស្មារតីឱ្យកាន់តែចុះខ្សោយទៅ ហើយនិងធ្វើខ្លួនឯងឱ្យមាននូវសេចក្តីប្រមាទកាន់តែខ្លាំងឡើង ។

សេចក្តីប្រមាទ មិនអាចនាំសត្វលោកឱ្យរួច

ចាកអំពីសេចក្តីទុក្ខលំបាកបានឡើយ ។

សិក្ខាបទទាំង៥ ដែលបានរៀបរាប់មកហើយនេះ គឺជាធមិសម្រាប់វាស់នូវគុណភាពរបស់មនុស្ស បើមិនមាននូវសីល៥នេះទេ ហៅថា "**មនុស្ស**" ពិតជាមិនពីរោះស្តាប់នោះទេ ។

ត្រីក្រឹមល្អស្រស់ព្រោះមានស្រកា បក្សីបក្សាល្អព្រោះលោមា
រាត្រីល្អស្រស់ព្រោះមានចន្ទ្រា មនុស្សពិតសោភាព្រោះមានសីល៥ ។

សាន~សុជា



## ៣~ចាគសម្បទា

*<u>ដល់ព្រមដោយការបរិច្ចាគទាន ។</u>*

ព្រះមានព្រះភាគទ្រង់ត្រាស់ នឹងទីឃជាណុថា *"ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគរួចស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ គួរដល់ស្មូម ត្រេកអរក្នុងការចែករំលែកនូវទាន ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា ចាគសម្បទា"*[១] ។

***ចាគសម្បទា*** ការលះរបស់ឱ្យទៅជាទានក្នុងទីនេះ សំដៅយកការលះពីរយ៉ាងគឺ ម្យ៉ាងលះទេយ្យវត្ថុ ម្យ៉ាងទៀតលះកិលេសដែលជាប់ជំពាក់ក្នុងវត្ថុនោះឯង

១-អង្គុត្តរនិ- អដ្ឋកនិ- សន្ធានវគ្គ បិដកលេខ៤៨ ទំព័រ២៥០ ។

ដោយមិនសង្ឃឹមការតបស្នងអ្វី អំពីអ្នកដទៃវិញនោះឡើយ។

## សប្បុរិសទាន៥យ៉ាង[១]

**ក/សទ្ធាយ ទានំ ទេតិ** ឱ្យទានដោយសទ្ធា។

ការឱ្យទានដោយសទ្ធា គឺឱ្យដោយមានការជឿជាក់ថា ផលរបស់ទានពិតជាមានដោយពិតប្រាកដ។

**ទ្រង់ត្រាស់អានិសង្សថា** "ម្នាលភិក្ខុទាំងឡាយ បុគ្គលឱ្យទានដោយសទ្ធា ដោយផលទាននោះ កើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង ជាបុគ្គលមានរូបល្អគួររមិលមើល

១-អង្គុត្តរនិ. បញ្ចកនិ. តិកណ្ឌកីវគ្គ បិដកលេខ៤៥ ចាប់ពីទំព័រ៨៨តទៅ។



ជាទីជ្រះថ្លា ប្រកបដោយភាពជាអ្នកមានសម្បុរល្អដ៏ក្រៃលែងផង"។

**ខ/សក្កច្ចំ ទានំ ទេតិ** ឱ្យទានដោយសេចក្តីគោរព។

ការឱ្យទានដោយគោរព គឺឱ្យដោយយកចិត្តទុកដាក់គោរពក្នុងទាន និងបុគ្គលដែលជាអ្នកទទួល ឬថាឱ្យដោយដៃខ្លួនឯង មិនមែនឱ្យដោយការបោះបោកជាដើមឡើយ។

**ទ្រង់ត្រាស់អានិសង្សថា** "ម្នាលភិក្ខុទាំងឡាយ បុគ្គលឱ្យទានដោយគោរព ដោយផលទាននោះ កើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង ពួកជនណាៗ ទោះកូនក្តី ប្រពន្ធក្តី ខ្ញុំក្តី

អ្នកបម្រើក្តី អ្នកធ្វើការងារក្តី របស់បុគ្គលនោះ ជនទាំងនោះ តែងស្តាប់ដោយល្អ ផ្ទៀងស្រោត្រតាំងចិត្តដើម្បីដឹងផង”។

**គ/កាលេន ទានំ ទេតិ** ឱ្យទានតាមកាល។

ការឱ្យទានតាមកាល គឺឱ្យទានតាមកាលដែលគួរឱ្យ។ កាលដែលគួរឱ្យទាន ឈ្មោះថា **កាលទាន**[១] មាន៥ យ៉ាងគឺ ឱ្យទានដល់អ្នកមកថ្មី១ ឱ្យទានដល់អ្នកមានដំណើរ១ ឱ្យទានដល់អ្នកមានជំងឺ១ ឱ្យទានក្នុងពេលអត់បាយ១ បានដំកល់ស្រូវថ្មី ផ្លែឈើដំបូងដល់បុគ្គលមានសីលទាំងឡាយជាដំបូង១។

**ទ្រង់ត្រាស់អានិសង្សថា** “ម្នាលភិក្ខុទាំងឡាយ

១-អង្គុត្តរនិ. បញ្ចកនិ. សុមនវគ្គ បិដកលេខ៤៤ ចាប់ពីទំព័រ៨១តទៅ។



បុគ្គលឱ្យទានតាមកាលដ៏គួរ ដោយផលទាននោះ កើតក្នុងទីណា១ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង ប្រយោជន៍គឺភោគៈដ៏ពោរពេញរមែងមកតាមកាលដ៏គួរដល់បុគ្គលនោះផង”។

**ឃ/អនុគ្គហិតចិត្តោ ទានំ ទេតិ** ឱ្យទានដោយចិត្តអនុគ្រោះ។

ការឱ្យទានដោយចិត្តអនុគ្រោះ គឺឱ្យដោយមិនមានចិត្តសោកស្តាយ ឬថាឱ្យដោយចង់ឱ្យអ្នកទទួលបាននូវសេចក្តីសុខសប្បាយ ដោយមិនចង់ឱ្យគេតបស្នងអ្វីមកវិញឡើយ។

**ទ្រង់ត្រាស់អានិសង្សថា** “ម្នាលភិក្ខុទាំងឡាយ បុគ្គលឱ្យទានដោយចិត្តអនុគ្រោះ ដោយផលទាននោះ

កើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង រមែងបង្អោនចិត្តទៅដើម្បីបរិភោគក្នុងកាមគុណ៥ ដ៏លើសលប់ផង"។

**ខ/អត្តានញ្ច បរញ្ច អនុបហច្ច ទានំ ទេតិ** ឱ្យទានដោយមិនបៀតបៀនខ្លួនឯង និងអ្នកដទៃ។

ការឱ្យទានដោយមិនបៀតបៀនខ្លួនឯង និងអ្នកដទៃ គឺសំដៅដល់ការឱ្យដោយមិនមើលងាយគុណទាំងឡាយ។

**ទ្រង់ត្រាស់អានិសង្សថា** "ម្នាលភិក្ខុទាំងឡាយ បុគ្គលឱ្យទានដោយមិនបានបៀតបៀនខ្លួនឯង និងអ្នកដទៃ ដោយផលទាននោះ កើតក្នុងទីណាៗ ជាបុគ្គល



ស្តុកស្តម្ភ មានទ្រព្យច្រើន មាន ភោគៈច្រើនផង សេចក្តីអន្តរាយ នៃភោគៈទាំងឡាយ មិនមានមកអំពីទីណាមួយ គឺអំពីភ្លើង អំពីទឹក អំពីស្តេច អំពីចោរ អំពីហេតុមិនជាទីស្រឡាញ់ និងអំពីមនុស្សជាទាយាទ"។

គេសង្កេតឃើញថា មនុស្សដែលទើបកើតមក តែងតែមានការយំនិងក្តាប់ដៃយ៉ាងណែន តែពេលដែលស្លាប់ទៅវិញតែងតែលាដៃ។

✍ ការកើតមកយំក្តាប់ដៃ ជាសញ្ញាប្រាប់យើងថា *"អ្វីៗក្នុងលោកនេះជារបស់អញទាំងអស់"*។

☞ ការស្លាប់ទៅវិញលាដៃ ជាសញ្ញាប្រាប់យើងទាំងអស់គ្នាថា *"ខ្ញុំយកអ្វីទៅមិនបាននោះទេ"*។

បុគ្គលឆ្លាត កាលបើផ្ទះត្រូវភ្លើងឆេះហើយ ត្រូវតែប្រញាប់ជញ្ជូនយកទ្រព្យ ដែលមានតម្លៃចុះចេញពីផ្ទះនោះ បើមិនដូច្នោះទេទ្រព្យនោះនឹងត្រូវឆេះអស់ទៅជាមួយនឹងផ្ទះមិនខានឡើយ យ៉ាងណាមិញ អត្តភាពនេះ ក៏ត្រូវភ្លើងជរា ភ្លើងព្យាធិ កំពុងតែដុតរោលរាល់តែថ្ងៃ មិនយូរប៉ុន្មានគង់តែដល់ថ្ងៃស្លាប់ដោយប្រាកដ បើមានទ្រព្យសម្បត្តិតែមិនបានបរិច្ចាគធ្វើទានដើម្បីជាកំណប់ជាប់ទៅតាមសន្តានទេ ទ្រព្យនោះក៏ត្រូវវិនាសអស់ទៅ នៅពេលដែលស្លាប់នោះឯង ហើយជីវិតពិតជាកំសត់ក្នុងសង្សារវដ្តមិនខាន។



ឱ្យទានទាន់មានទ្រព្យនិងជីវិត ត្រូវតែចេះគិតកុំនៅកន្តើយ
សន្សំកុសលបង្ការឱ្យហើយ ព្រោះមិនដឹងឡើយថាស្លាប់ថ្ងៃណា។

សាន~សុជា

## ៤-បញ្ញាសម្បទា

*ដល់ព្រមដោយបញ្ញា។*

ពាក្យថា "**បញ្ញា**" មានបទវិគ្រោះថា "**បជានាតីតិ** > **បញ្ញា** = ឈ្មោះថា **បញ្ញា** ព្រោះអត្ថថា សេចក្ដីដឹងទូទៅ" សំដៅដល់ការដឹងនូវសេចក្ដីពិតតាមធម្មជាតិ គឺរមែងដឹងទូទៅនូវអរិយសច្ចៈទាំងឡាយដោយន័យថា នេះជាទុក្ខ នេះជាហេតុនាំឱ្យកើតទុក្ខជាដើម។

**បញ្ញា** គឺជាធម្មជាតិដែលដឹងបាន នូវសង្ខារធម៌ទាំងឡាយ ដែលស្ថិតនៅក្នុងភាពជា **អនិច្ចំ** (មិនទៀង) **ទុក្ខំ** (ជាទុក្ខ) និងជា **អនត្តា** (មិនមែនខ្លួន)។



**បញ្ញា** កាលកើតឡើងហើយ រមែងវិនិច្ឆ័យ បានថា អ្វីពិត អ្វីមិនពិត អ្វីល្អ អ្វីអាក្រក់ អ្វីត្រូវ អ្វីខុស អ្វីគួរ អ្វីមិនគួរ អ្វីជាគុណ អ្វីជាទោស និងអ្វីជា ប្រយោជន៏ អ្វីមិនមែនជាប្រយោជន៏ ជាដើម។

**បញ្ញា** រមែងដឹងនូវហេតុផលនៃធម្មជាតិ គឺដឹងថា អ្វីៗទាំងអស់ដែលកើតឡើង សុទ្ធតែជាផលរបស់ហេតុ ហេតុយ៉ាងណាផលក៏យ៉ាងនោះ បើហេតុមិនមាន ទោះបីបង្ខំក៏មិនអាចកើតឡើងបាន។ កាលបានដឹងយ៉ាងនេះ ចិត្តរមែងផុតស្រឡះចាកការកង្វល់ ព្រោះយល់ច្បាស់ថា អ្វីដែលកើតឡើងចំពោះជីវិតសុទ្ធតែសមហេតុផលទាំងអស់។

**បញ្ញាសម្បទា** ដែលជាគុណសម្បត្តិរបស់

ព្រះអរិយសាវ័ក គឺដឹងការកើត និងការសូន្យទៅនៃសង្ខារធម៌ ដឹងគតិធម្មតារបស់លោកនិងជីវិត ដែលមានការកើតចាស់ឈឺស្លាប់ ។ អ្វីៗដែលកើតឡើងរមែងមានការវិនាសទៅវិញរលត់ទៅវិញជាធម្មតា ហើយរំលត់នូវសេចក្តីប្រកាន់ ដោយបានដឹងច្បាស់ថា សង្ខារធម៌ទាំងពួងមិនគួរប្រកាន់ថា ជារបស់ស្ថិតស្ថេរមាំមួន (**យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ** = ធម្មជាតិណាមានការកើតឡើងជាធម្មតា ធម្មជាតិនោះទាំងអស់ រមែងរលត់ទៅវិញជាធម្មតា) ។

កាលបើមិនមានបញ្ញាយល់ដឹងអំពីលោក និងជីវិតតាមសេចក្តីពិត ពោលគឺមិនបានឃើញនូវសភាវធម៌ដែលមានការកើតឡើងនិងរលត់ទៅ មិនបាន



កំណត់ដឹងនូវសភាពធម្មតារបស់សង្ខារធម៌ ទាំងឡាយទេ ហើយថែមទាំងមិនបានសិក្សាឱ្យយល់ដឹងអំពីអ្វីដែលជាសេចក្តីសុខប្រាសចាកទោស ប្រាសចាកកង្វល់ប្រាសចាកការហួងហែងទេ ប្រាកដជានឹងឱ្យតំលៃតែទៅលើកាមគុណប៉ុណ្ណោះ ថាជាសេចក្តីសុខស្រួលដ៏កំពូល ។

**បញ្ញា** ដែលនឹងអាចកើតឡើងបាន មិនមែនកើតឡើងដោយឯងៗ ឬក៏ដោយអាស្រ័យការអង្វរករសុំអំពីអ្នកដទៃនោះឡើយ ។

## ហេតុនាំឱ្យកើតបញ្ញា៣យ៉ាង[១]

**ក-សុតមយបញ្ញា** បញ្ញាកើតឡើងដោយសារការស្តាប់ឬរៀនសូត្រពីអ្នកដទៃ ។

---

១-គម្ពីរវិសុទ្ធិមគ្គភាសាបាលី ក្បាលទី៣ ខន្ធនិទ្ទេស ទំព័រទី៨៨៣ ។

**សុតៈ** (ការស្តាប់) គឺជាឧបករណ៍ដ៏សំខាន់របស់បញ្ញា ឯចំណែកបញ្ញាឱ្យសេចក្តីសម្រេចដល់សុតៈ ពោលគឺបញ្ញាជាផលរបស់សុតៈនោះឯង។

ព្រះមានព្រះភាគ ទ្រង់ត្រាស់នូវអានិសង្សនៃការស្តាប់ធម៌មាន៥យ៉ាងគឺ[១]

(១)- **អស្សុតំ សុណាតិ** អ្នកស្តាប់តែងបានស្តាប់រឿងមិនទាន់បានស្តាប់។

(២)- **សុតំ បរិយោទបេតិ** រឿងណាដែលធ្លាប់ស្តាប់ហើយ តែមិនទាន់ចូលចិត្តច្បាស់នឹងចូលចិត្តច្បាស់ឡើងបាន។

(៣)- **កង្ខំ វិហនតិ** កម្ចាត់បង់នូវសេចក្តីសង្ស័យចេញបាន។

---

១-អង្គុត្តរនិ. បញ្ចកនិ. កិមិលវគ្គ បិដកលេខ៤៥ ទំព័រទី២៣៨។



(៤)- **ទិដ្ឋឹ ឧជុំ ករោតិ** រមែងធ្វើសេចក្តីយល់ឃើញឱ្យត្រង់។

(៥)- **ចិត្តមស្ស បសីទតិ** ចិត្តអ្នកស្តាប់រមែងជ្រះថ្លា។

**ខ~ចិន្តាមយបញ្ញា** បញ្ញាកើតឡើងដោយការគិតពិចារណា។

កាលបានឮបានដឹងអ្វីហើយ ស្រាប់តែប្រកាន់ជឿភ្លាម ដោយមិនមានការគិតពិចារណាឱ្យបានល្អិតល្អន់ ពិតជាមិនប្រពៃឡើយ ព្រោះអាចថានឹងខុសចាកការពិតបាន។

សម័យមួយ ពួកកាលាមក្សត្រទាំងឡាយបានស្តាប់នូវវាទៈនៃសាសនាផ្សេងៗ ដែលសុទ្ធតែ

អះអាងថាខ្លួនបរិសុទ្ធ ពួកកាលាមក្សត្រទាំងឡាយនោះមិនដឹងថាត្រូវជឿវាទៈនៃសាសនាណា ទើបចូលទៅគាល់ព្រះមានព្រះភាគ.......។

ព្រះសម្ពុទ្ធ ទ្រង់ត្រាស់នឹងកាលាមក្សត្រទាំងឡាយថា[១]

"ម្នាលកាលាមក្សត្រទាំងឡាយ អ្នកទាំងឡាយចូរមក

-អ្នកកុំប្រកាន់ដោយគ្រាន់តែឮតាមគ្នា

-កុំប្រកាន់តាមពាក្យបរម្បរា

-កុំប្រកាន់ថាបានឮដូច្នេះ

-កុំប្រកាន់ដោយអាងក្បួនតម្រា

-កុំប្រកាន់តាមហេតុដែលត្រិះរិះ

១-អង្គុត្តរនិ. ទុតិយបណ្ណា. មហាវគ្គ តិកនិបាត បិដកលេខ៤១ ទំព័រ២១៨។



-កុំប្រកាន់ដោយកាត់ដំរូយផ្សេងៗ

-កុំប្រកាន់ដោយគ្រាន់តែត្រិះរិះនូវអាការៈ

-កុំប្រកាន់ដោយសេចក្ដីពេញចិត្ត តាមការពិនិត្យសមនឹងសេចក្ដីយល់ឃើញ

-កុំប្រកាន់ដោយយល់ថាមានសភាពគួរ (ជឿ)

-កុំប្រកាន់ដោយគិតថា សមណៈ (នេះ) ជាគ្រូរបស់យើង

ម្នាលកាលាមក្សត្រទាំងឡាយ កាលបើអ្នកទាំងឡាយដឹងដោយខ្លួនឯងថា ធម៌ទាំងនេះជាអកុសល ធម៌ទាំងនេះប្រកបដោយទោស ធម៌ទាំងនេះអ្នកប្រាជ្ញតិះដៀល ធម៌ទាំងនេះបុគ្គលបានសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជា

ប្រយោជន៍ ដើម្បីសេចក្តីទុក្ខ។ ម្នាលកាលាមក្សត្រទាំងឡាយ ក្នុងកាលនោះ អ្នកទាំងឡាយត្រូវលះបង់ចោលចេញ"។

ក្នុងពុទ្ធភាសិតខាងលើនេះ បានចង្អុលបង្ហាញឱ្យសត្វលោកមានការគិតពិចារណាឱ្យបានល្អិតល្អន់ មុននឹងសម្រេចចិត្តជឿទៅលើរឿងអ្វីមួយ ដាច់ខាតកុំជឿដោយគ្មានការគិតពិចារណាឱ្យសោះ។

**គ. ភាវនាមយបញ្ញា** បញ្ញាសម្រេចដោយការចម្រើនភាវនា សំដៅដល់ការអប់រំចម្រើន **វិបស្សនា**។

ដើម្បីឱ្យបញ្ញាកាន់តែមានកម្លាំង ត្រូវតែមានការអប់រំចម្រើន សតិប្បដ្ឋានវិបស្សនាដោយអត់ធន់



ក្នុងការប្រាថ្នាចង់បាននូវផលច្រើនៗ ប៉ុន្តែអានិសង្សដែលទទួលបានគួរជាទីគាប់ចិត្តនោះ គឺការមានសតិនិងបញ្ញាដែលចម្រើនឡើង ឃើញច្បាស់នូវសង្ខារធម៌នោះឯង។

អ្នកអប់រំចម្រើនវិបស្សនា ត្រូវតែជាអ្នកត្រង់ចំពោះខ្លួនឯង គឺដឹងថានៅមានកិលេសគ្របសង្កត់ញាំញីចិត្តរាល់ថ្ងៃ ហើយក៏មិនប្រាថ្នាឱ្យកិលេសនោះអស់ទៅដោយមិនមានការសិក្សារលឹកដឹងនោះឡើយ។

គ្រប់បុថុជ្ជនទាំងអស់ មិនអាចក្លាយទៅជាព្រះអរហន្តភ្លាមៗបានឡើយ ទាល់តែមានការរំលត់នូវលោភៈដែលកើតរួមជាមួយនឹងសក្កាយទិដ្ឋិ ដែលប្រកាន់នូវសភាវធម៌ដែលកើតរួមគ្នា ថាជាតួខ្លួន ជា

សត្វ ជាបុគ្គលឱ្យអស់ជាសមុច្ឆេទសិន ទើបកិលេសដែលនៅសល់ដទៃៗទៀត នឹងរំលត់ដាច់អស់ទៅជាសមុច្ឆេទ បន្តបន្ទាប់តាមលំដាប់បាន ។

ប្រសិនបើមិនអប់រំចម្រើនបញ្ញា រហូតដល់បានឃើញថា ការឃើញ ការឮ...... ការដឹងរឿងរ៉ាវផ្សេងៗ ត្រឹមតែជាសភាវធម៌ មិនមែនជាតួខ្លួន សត្វបុគ្គល ដែលកើតឡើងព្រោះបច្ច័យ ហើយក៏រលត់ទៅវិញយ៉ាងឆាប់រហ័សដូច្នេះទេ ពិតជាមិនអាចរំលត់នូវកិលេសទាំងឡាយដូចជាការស្រឡាញ់ ស្អប់ គាប់ទាស់....... ជាដើមបានឡើយ ។

ផ្លូវប្រតិបត្តិដ៏ជាក់លាក់ ដែលព្រះមានព្រះភាគទ្រង់ត្រាស់សំដែង ដើម្បីឱ្យសត្វលោកប្រតិបត្តិ



ឱ្យរួចផុតទុក្ខនោះ មានតែ១គត់ គឺអរិយមគ្គដែលប្រកបដោយអង្គ៨ប្រការគឺ[១]

(១) **សម្មាទិដ្ឋិ** ប្រាជ្ញាយល់ឃើញត្រូវ បានដល់បញ្ញាចេតសិក ។

(២) **សម្មាសង្កប្បៈ** សេចក្តីត្រិះរិះត្រូវ បានដល់វិតក្កចេតសិក ។

(៣) **សម្មាវាចា** សំដីត្រូវ បានដល់ សម្មាវាចា-ចេតសិក ។

(៤) **សម្មាកម្មន្តៈ** ការងារត្រូវ បានដល់ សម្មា-កម្មន្តចេតសិក ។

(៥) **សម្មាអាជីវៈ** កិរិយាចិញ្ចឹមជីវិតត្រូវ បានដល់សម្មាអាជីវចេតសិក ។

---

១-វិន័យបិដក មហាខន្ធកៈ ធម្មចក្កប្បវត្តនសូត្រ បិដកលេខ៦ ទំព័រទី២៩ ។

(៦) **សម្មាវាយាមៈ** សេចក្តីព្យាយាមត្រូវ បានដល់វិរិយចេតសិក។

(៧) **សម្មាសតិ** សេចក្តីរលឹកត្រូវ បានដល់សតិចេតសិក។

(៨) **សម្មាសមាធិ** កិរិយាតម្កល់ចិត្តឱ្យនឹងត្រូវ បានដល់ឯកគ្គតាចេតសិក។

មុនពេលដែលលោកុត្តរចិត្ត កើតឡើង ចេតសិកជាអង្គមគ្គ៥ (វៀរវិរតិចេតសិក៣ ព្រោះវិរតិចេតសិក៣នេះ កើតព្រមគ្នាទាំង៣បានតែនៅក្នុងលោកុត្តរចិត្តប៉ុណ្ណោះ) រមែងកើតឡើងធ្វើកិច្ចរួមគ្នាក្នុងខណៈដែលសតិរលឹកដឹងលក្ខណៈ នៃសភាវធម៌ដែលជានាមធម៌ ឬរូបធម៌យ៉ាងណាមួយ តាមភ្នែក



តាមត្រចៀក តាមច្រមុះ តាមអណ្តាត តាមកាយ ឬតាមចិត្ត ហើយបញ្ញាចេតសិកដែលកើតរួមនឹងសម្មាសតិក្នុងខណៈនោះ ក៏ផ្តើមសង្កេតពិចារណា ដឹងលក្ខណៈនៃនាមធម៌ ឬរូបធម៌នោះៗបន្តិចម្តងៗ សន្សឹមៗ ជារឿយៗទៅរហូតបានដឹងច្បាស់ ថាជានាមធម៌ ឬរូបធម៌តាមសេចក្តីពិត។

ការចម្រើនសតិប្បដ្ឋានវិបស្សនា ដែលជាការអប់រំចម្រើនបញ្ញា ដើម្បីឱ្យដឹងច្បាស់នូវអរិយសច្ចធម៌នោះ នាំឱ្យកើតបរិញ្ញា៣គឺ[១]

**ញាតបរិញ្ញា** បញ្ញាដែលប្រចក្សលក្ខណៈនៃនាមធម៌និងរូបធម៌ដោយប្រាកដច្បាស់ថា មិនមែនជាតួខ្លួន ដោយ**នាមរូបបរិច្ឆេទញាណ**ជាដើមទៅ។

---

១-ខុទ្ទកនិ. មហានិទ្ទេស បិដកលេខ៦៤ ចាប់ពីទំព័រ១០៤ តទៅ

**តីរណបរិញ្ញា** គឺបញ្ញាដែលកំណត់ដឹងនូវនាមរូបថា មិនទៀង ជាទុក្ខ ជារោគ ជាពក ជាព្រួញ ជាសេចក្ដីលំបាក ជាអាពាធ ........ជាគ្រឿងកើតឡើង ជាគ្រឿងដល់នូវការវិនាស...ដោយ**ឧទយព្វយញ្ញាណ**។

**បហានបរិញ្ញា** គឺការពិចារណានូវសេចក្ដីរលត់ទៅនៃនាមធម៌និងរូបធម៌ រហូតដឹងច្បាស់នូវការរលត់ទៅនៃនាមធម៌និងរូបធម៌ដោយ**ភង្គញ្ញាណ** ដោយបញ្ញាដែលដឹងជុំវិញទូទៅកាន់តែចម្រើនឡើង ក៏ផ្ដើមលះបង់នូវសេចក្ដីត្រេកអរ ក្នុងនាមធម៌និងរូបធម៌ ព្រោះឃើញទោសនៃនាមរូបកាន់តែច្បាស់ឡើងៗ ជា**បហានបរិញ្ញា** ជាដើមទៅរហូតដល់**មគ្គញ្ញាណ**។

នៅក្នុងបដិច្ចសមុប្បាទ ព្រះមានព្រះភាគទ្រង់



ត្រាស់សំដែងអំពីឫសគល់នៃសង្សារវដ្ដ គឺអវិជ្ជា។

អវិជ្ជា គឺជាមេនៃសង្ខារធម៌ទាំងពួង ហើយសង្ខារធម៌គ្រប់ប្រការដែលកើតឡើងទាំងអស់ សុទ្ធតែជាទុក្ខ ព្រោះតាំងនៅក្នុងសភាពមិនទៀង មានការប្រែប្រួល វិនាសទៅវិញដោយឥតមានសេសសល់ តែថា បើអវិជ្ជានៅមាន សង្ខារធម៌គ្រប់ប្រការតែងតែកើតរលត់ៗ ក្នុងសង្សារវដ្ដឥតមានទីបញ្ចប់ឡើយ។

ធម្មជាតិដែលអាចកម្ចាត់បង់នូវ**អវិជ្ជា**បាន គឺមានតែ**វិជ្ជា**ប៉ុណ្ណោះ អង្គធម៌បានដល់**បញ្ញាចេតសិក**។ ដូច្នេះ ក្រៅពីការអប់រំចម្រើននូវបញ្ញាហើយ មិនមានវិធីផ្សេងដទៃណាដើម្បីកម្ចាត់បង់ នូវមោហៈ អវិជ្ជាបានឡើយ។

**បញ្ញា** បានផ្តល់ឱ្យនូវភាពត្រឹមត្រូវដល់គុណសម្បត្តិដទៃៗច្រើនទៀត ។

**បញ្ញា** បានធ្វើឱ្យសទ្ធា ជាសទ្ធាដែលត្រឹមត្រូវទៅតាមសេចក្តីពិត មិនភ្លាំងភ្លាត់ទៅជារឿងភ្ញាក់ផ្អើលផ្សេងៗ ។

**បញ្ញា** ធ្វើឱ្យសីល ជាសីលដែលជាទីត្រេកអររបស់ព្រះអរិយៈទាំងឡាយ មិនក្លាយទៅជាសីលព្វត-បរាមាស ។

**បញ្ញា** គឺជាគុណសម្បត្តិដ៏សំខាន់បំផុតរបស់ព្រះអរិយសាវ័កទាំងឡាយ និងជាទិសដៅនៃការហ្វឹកហាត់អប់រំខ្លួនរបស់ព្រះអរិយសាវ័កជាបន្តទៅ រហូតដល់អស់ទៅនៃអវិជ្ជា ដោយឥតមានសេសសល់ ។



**បញ្ញា** គឺជាភ្នែកដ៏មានសិរីអាចឆ្លុះមើលឃើញនូវបក្ខពួករបស់សត្រូវ គឺកិលេសគ្រប់ប្រការបាន និងជាអាវុធដ៏ប្រសើរអាចកាប់ប្រហារនូវមេខ្លោងរបស់បក្ខពួកសត្រូវ គឺអវិជ្ជាឱ្យអស់ទៅបាន ។

ដូច្នេះ **បញ្ញា** ទើបជាគុណជាតិដ៏ប្រសើរដែលអ្នកប្រាថ្នាសុខត្រូវតែអប់រំចម្រើន ផ្តើមឡើងដោយការមានសទ្ធា និងការស្តាប់ជាដើម ។

*បុគ្គលមានបញ្ញា*
*រមែងមានខ្លួនឯងជាទីពឹង ។*
*តែបុគ្គលល្ងង់ខ្លៅ*
*រមែងមានខ្លួនឯងជាសត្រូវដ៏ក្រៃលែង ។*

ផ្ទៃមេឃងងឹតព្រោះខ្វះពន្លឺ តែក្លាយជាភ្លឺព្រោះមានសុរិយា
សត្វលោកងងឹតព្រោះមានមោហា បើមានបញ្ញាភ្លឺថ្លាជាងថ្ងៃ។

សាន-សុជា



## សម្បរាយិកត្ថប្រយោជន៍
## ជាប្រយោជន៍ថ្នាក់កណ្តាល

សម្បទា៤យ៉ាង មានសទ្ធាសម្បទាជាដើម ដែលបានរៀបរាប់មកហើយនេះ ចាត់ជាប្រយោជន៍ថ្នាក់កណ្តាល ឬថាជាប្រយោជន៍ទី២ ដែលសត្វលោកអ្នកនៅមានសេចក្តីតក់ស្លុត ត្រូវតែបំពេញដើម្បីជាកំណប់ទ្រព្យជាប់តាមសន្តាន តទៅក្នុងភពខាងមុខទៀត ព្រោះប្រយោជន៍ទី២នេះ មានអំណាចអាចរារាំង មិនឱ្យសត្វលោកធ្លាក់ទៅកាន់អបាយភូមិបាន ហើយនឹងអាចផ្តល់ឱ្យនូវកំណើតថ្មីក្នុងសុគតិភព ដល់សត្វលោកបានទៀត។

ប្រយោជន៍ថ្នាក់កណ្តាលនេះ មិនមែនត្រឹមតែ

ជាស្ពានចម្លងសត្វលោក ឱ្យរួចអំពីអន្លង់នៃអបាយភូមិ ប៉ុណ្ណោះទេ សឹងជាផ្លូវប្រតិបត្តិដើម្បីរលាស់ខ្លួនចេញ ចាកអំពីសេចក្តីទុក្ខគ្រប់ប្រការ ក្នុងសង្សារវដ្តបានទៀតផង ។

*បើចង់បានសុខ កុំសាងពូជទុក្ខឱ្យដល់ខ្លួនឯង ។*

| | | |
|---|---|---|
| បើចង់បានសុខ | ត្រូវខំសម្រុក | តគ្រុកធ្វើបុណ្យ |
| លាចាកពីបាប | អំពើទារុណ | ផ្លាស់មកធ្វើសុន្ទរ៍ |
| | ទើបគុណល្អគាប់ ។ | |

សាន~សុជា



## III-បរមត្ថប្រយោជន៍

*ប្រយោជន៍គឺព្រះនិព្វាន ។*

**និព្វាន** គឺជាឈ្មោះនៃសេចក្តីសុខដ៏កំពូល និងចុងក្រោយបង្អស់ ដែលសត្វលោកនឹងត្រូវជួបប្រទះ ព្រោះអាស្រ័យការប្រកប នូវប្រយោជន៍ថ្នាក់ក្រោម និងប្រយោជន៍ថ្នាក់កណ្តាល ដែលបានរៀបរាប់រួចមក ហើយនោះឯង ។

**និព្វាន** ជាសេចក្តីសុខដែលមានពិត ដោយ ប្រាសចាកការហួងហែង ប្រាសចាកការកង្វល់ ប្រាស ចាកការភ័យតក់ស្លុតគ្រប់ប្រការ ។

**និព្វាន** មិនមែនជាដែនដីប្រទេស គេហដ្ឋាន វិមាន ឬថាជាពិភពរបស់ព្រះអាទិទេពណាឡើយ ។

**និព្វាន** មិនមែនជាឋានដែលត្រូវមានព្រលឹងសោយសុខយ៉ាងណានីមួយ ដូចគំនិតសត្វលោកដែលជ្រោកជ្រាកទៅដោយកិលេសគិតស្រម័យនោះទេ ។

**និព្វាន** មិនមែនជាកន្លែងដែលត្រូវទៅដល់ដោយការដើរ ការជិះយាន ឬក៏ដោយការប្រើឫទ្ធិហោះហើរទៅជាដើមនោះឡើយ ។

តែថា **និព្វាន** គឺសំដៅទៅលើការរលត់យ៉ាងកំពូល គឺសូន្យចាកកំដៅ សូន្យចាកការដុត សូន្យចាកការចាក់ដោត សូន្យចាកសត្វ បុគ្គល តួខ្លួន សូន្យចាកការប្រកាន់ សូន្យចាកភាពរឹតរួត សូន្យចាកការតាក់តែងរបស់បច្ច័យគ្រប់យ៉ាង ។

**និព្វាន** គឺជាសភាពនៃសេចក្តីរលត់យ៉ាង



កំពូលនូវសេចក្តីទុក្ខសោកគ្រប់ប្រការ ដែលត្រូវបង្កើតឡើងដោយស្នាដៃរបស់កិលេស ។ ម្យ៉ាងទៀត ចំណងនៃកិលេសគឺសំយោជនៈ ដែលចងរឹតរួតចិត្តសន្តានរបស់សត្វលោកអស់កាលជាអង្វែងមក ក៏ត្រូវបានដាច់ជ្រុះចាកសន្តានជាបណ្តើរៗ ចាប់តាំងពីមគ្គថ្នាក់ក្រោមឡើងទៅជាលំដាប់ ។

ការបានដល់នូវព្រះនិព្វាន មិនមែនសំដៅទៅលើតែសមុច្ឆេទមរណៈ ដែលជាសេចក្តីស្លាប់ចុងក្រោយបង្អស់របស់ព្រះអរហន្តប៉ុណ្ណោះទេ សូម្បីលោកកំពុងរស់នៅក៏ឈ្មោះថា លោកបានដល់នូវព្រះនិព្វានដែរ ដូច្នេះទើបព្រះនិព្វានមាន២យ៉ាងគឺ **សឧបាទិសេស-និព្វានធាតុ១** និង**អនុបាទិសេសនិព្វានធាតុ១** ។

## និព្វានធាតុមាន២យ៉ាងគឺ

**១. សឧបាទិសេសនិព្វានធាតុ** និព្វានធាតុដែលនៅសល់វិបាកខន្ធនិងកម្មជរូប ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា[១] "ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអរហន្តខីណាស្រព មានព្រហ្មចរិយៈប្រព្រឹត្តរួចហើយ មានសោឡសកិច្ចបានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ ដោយលំដាប់ មានសំយោជនៈក្នុងភពអស់ហើយ ផុតស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ ប៉ុន្តែឥន្ទ្រិយទាំង ៥ របស់ព្រះអរហន្តខីណាស្រពនោះ តាំងនៅដដែល អរហន្តខីណាស្រពនោះ នៅ

១-ខុទ្ទកនិកាយ ឥតិវុត្តកៈ បិដកលេខ៥៣ ចាប់ពីទំព័រទី៥០តទៅ ។



សោយអារម្មណ៍ ដែលពេញចិត្ត នឹងមិនពេញចិត្ត សោយសុខ នឹងទុក្ខ ព្រោះឥន្ទ្រិយទាំង ៥ នោះ មិនមានសេចក្តីថ្នាំងថ្នាក់ទេ ។ ការអស់រាគៈ អស់ទោសៈ អស់មោហៈ របស់ព្រះអរហន្តនោះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សឧបាទិសេសនិព្វានធាតុ**" ។

ពាក្យថា **សឧបាទិសេសនិព្វានធាតុ** បានមកពី **ស** + **ឧបាទិ** + **សេស** + **និព្វាន** + **ធាតុ** ។

**ឧបាទិ** ជាសភាវធម៌ដែលត្រូវបានឧបាទានមានកាមជាដើមចាប់ប្រកាន់ទុកយ៉ាងមាំ ។

**ឧបាទិ** ជាឈ្មោះនៃបញ្ចក្ខន្ធ ។

**ឧបាទិសេស** សំដៅយកបញ្ចក្ខន្ធដែលនៅ

សល់ក្រៅពីកិលេស ។

**សឧបាទិសេសនិព្វាន** គឺសំដៅយកនិព្វាន ដែលប្រព្រឹត្តទៅជាមួយនឹង **ឧបាទិសេស** នោះឯង ។

**សឧបាទិសេសនិព្វាន** នេះ សំដៅដល់ និព្វានដែលរំលត់កិលេស ក្នុងសន្តាននៃព្រះអរិយៈ ទាំងឡាយ ដែលលោកបានសម្រេចក្នុងពេលដែល អរហត្តមគ្គកើតឡើង ហើយប្រហារកិលេសឱ្យអស់ ដោយឥតមានសេសសល់ ។

កាលព្រះមានព្រះភាគទ្រង់ត្រាស់ដឹង ក្រោមម្លប់ព្រះពោធិព្រឹក្សនោះ ព្រះអង្គទ្រង់សម្រេចនូវ **សឧបាទិសេសនិព្វាន** នេះឯង។ កិលេសនិងធម៌ (ដែលបានដល់ ចិត្ត និងចេតសិកដទៃៗ) ដែលកើតរួម



នឹងកិលេសនោះក៏រលត់អស់ នឹងមិនកើតទៀតឡើយ ប៉ុន្តែនៅមានខន្ធ គឺចិត្តចេតសិក និងរូបកើតរលត់បន្តគ្នាគ្រប់ពេល តែថាមិនមានកិលេសជាគ្រឿងក្តៅ ជាគ្រឿងដោតក្រង ជាគ្រឿងកង្វល់ ជាគ្រឿងរំខាន ជាគ្រឿងដុត ជាគ្រឿងចំណាក់ ជាគ្រឿងជល់ ជាគ្រឿងរុកកួន ...........សន្តានចិត្តទៀតឡើយ ។

សព្វថ្ងៃនេះ បើទុកជាគ្មានអ្នកណាប្រាប់ ក៏យើងអាចដឹងបានថា សត្វលោកកំពុងតែរស់នៅក្នុងកំដៅ ហើយកំដៅនេះកាន់តែមានកំណើនជាងមុនខ្លាំងឡើងៗ។ នេះក៏គ្មានព្រោះអ្វីដទៃទេ គឺព្រោះតែ **ភ្លើងគឺរាគៈ ភ្លើងគឺទោសៈ ភ្លើងគឺមោហៈ**នៅក្នុងចិត្តវិញ្ញាណរបស់សត្វលោក ចេះតែមានចំហេះខ្លាំងឡើងៗ

ដោយហេតុថា មនុស្សលោកកាន់តែឆ្លាតចេះវិធីផ្គុំភ្លើង ឱ្យកាន់តែខ្លាំងឡើង តែខ្វះខាតនូវវិធីពន្លត់។

ព្រះនិព្វាន គឺជាសភាវធម៌ដែលនៅឆ្ងាយសម្រាប់សត្វលោក ដែលជ្រោកជ្រាកដោយកិលេស ហើយដែលមិនបានសិក្សាអំពីធម្មជាតិ តែព្រះនិព្វាន ឈ្មោះថានៅជិតសត្វលោក អ្នកអប់រំចម្រើនបញ្ញា ដឹងលក្ខណៈរបស់ធម្មជាតិទាំងអស់ ដែលសុទ្ធតែជាសង្ខារធម៌តាំងនៅក្នុងភាពមិនទៀង ជាទុក្ខ និងជាអនត្តា។ កាលបើបានដឹងនូវទោសរបស់សង្ខារហើយ ចិត្តរមែងគ្រាកចេញអំពីឆន្ទរាគៈ ក្នុងរបស់ទាំងពួង កាលបើចិត្តស្ងប់ហើយ គួបផ្សំនឹងការចង្អុលបង្ហាញទិសរបស់ព្រះសម្មាសម្ពុទ្ធ គឺការស្តាប់ធម៌របស់ព្រះអង្គ



បញ្ញាដែលធ្លាប់សន្សំមកអស់កាលជាអង្វែង ក៏មានកម្លាំងរហូតបានក្លាយជាបញ្ញាពលៈ អាចបង្អោនទៅរកព្រះនិព្វានបាន។

ការដែលសត្វលោក នាំគ្នាស្វាបអង្អែលនូវបញ្ចកាមគុណ បង្កើននូវសេចក្តីត្រេកអរដោយឆន្ទរាគៈ គឺជាការដើរឃ្វាងផ្លូវទៅកាន់និព្វាន ហើយកាន់តែឆ្ងាយទៅៗ ធ្លាក់ចូលទៅក្នុងផ្លូវកន្តារ ឈ្មោះថាសង្សារវដ្ត ដែលឥតមានទីបញ្ចប់ តែថាបើសត្វលោកមានសតិស្មារតី ផ្តើមឃើញទោសរបស់កាមគុណគ្រប់ប្រការ រៀនលះបង់នូវការស្រឡាញ់ ស្អប់ គាប់ ទាស់ ដោយឃើញថា អ្វីៗទាំងអស់ដែលបានជួបប្រទះ សុទ្ធតែតាំងនៅក្នុងត្រៃលក្ខណ៍ ពេលនោះ ព្រះនិព្វានឈ្មោះថានៅ

ជិត ព្រោះព្រះនិព្វាន សំដៅត្រង់ការដែលរំលត់កិលេសគ្រប់ប្រការ ព្រមជាមួយបញ្ញាមានកម្លាំងនោះឯង។

ក្នុងសកលលោក បានក្លាយទៅជារបស់មានចំហេះ មានកំដៅ ទាំងមនុស្ស ទាំងសត្វ ទាំងសកល-ធាតុ ព្រោះអ្វី? ព្រោះមនុស្សក្នុងពិភពលោកនាំគ្នាស្ទាបអង្អែលនូវបញ្ចកាមគុណ នាំគ្នាបម្រើសេចក្ដីសប្បាយបោកប្រាស់ប្រកបដោយចិត្ត សឹងពោរពេញទៅដោយរាគៈ ទោសៈ មោហៈ លើសជាងសម័យមុន ១ជា១០ ឬ១ជា២០។ ដរាបណាសត្វលោកនៅមានគំនិតយល់ខុស នៅតែគ្មានសម្មាទិដ្ឋិដូច្នេះ ភាពត្រជាក់ត្រជុំនៃព្រះនិព្វាន មិនអាចកើតមានបានឡើយ។

ក្នុងបច្ចុប្បន្ននេះ មនុស្សបានតែនាំគ្នាជ្រួល



ច្របល់ ពពាក់ពពូន ជំពាក់ជំពិនលើទង្វើដុតបំផ្លាញខ្លួនឯង គឺនាំគ្នាថ្ងូរ នាំគ្នាជូរចត់ក្នុងជីវិតរៀងៗខ្លួន តែគ្មាននឹកស្រម័យដល់ព្រះនិព្វានឡើយ ដោយសេចក្ដីថាសកលសត្វ មិនបានទទួលអ្វីពីព្រះនិព្វានសូម្បីបន្តិចបន្តួចឡើយ ទោះណាជាព្រះនិព្វានមាននៅគ្រប់ទីកន្លែងគ្រប់ពេលវេលាយ៉ាងណាក៏ដោយ។

គំហើញដ៏ឆោតល្ងង់របស់សត្វទាំងឡាយ បានបង្កើតឱ្យគេនូវគំនិតថា របស់ផ្សេងៗដែលជាគ្រឿងបម្រើសេចក្ដីសប្បាយរបស់ខ្លួន ឬដែលខ្លួនយកមកប្រើដើម្បីបម្រើសេចក្ដីសប្បាយនោះ គឺជាគំនិតដែលត្រឹមត្រូវ តែគំនិតសច្ចធម៌វិញឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ថាសត្វលោកទេតើ ដែលយកខ្លួនឯងទៅបម្រើរបស់ទាំង

នោះ ក្នុងក្របខ័ណ្ឌនៃការបម្រើតណ្ហារបស់ខ្លួនឯង ។

សេចក្តីសុខ ដែលកើតឡើងដោយអំណាចតណ្ហាទាំងអស់ សុទ្ធតែមានការប្រែប្រួលនិងបញ្ចប់ទៅវិញដោយសេចក្តីសោកសង្រេង តែសេចក្តីសុខដែលកើតឡើងជាមួយនឹងការលះបង់ រួមជាមួយនឹងបញ្ញាទើបជាសេចក្តីសុខពិត ព្រោះមិនមានការអាឡោះអាល័យស្តាយក្រោយ ដូច្នេះការអប់រំចម្រើននូវបញ្ញាដើម្បីលះបង់នូវតណ្ហា ទើបជាបដិបទាទៅរកសេចក្តីសុខពោលគឺព្រះនិព្វានមែន ។

សេចក្តីសុខក្នុងកាមគុណ គឺជាសេចក្តីសុខដែលញាប់ញ័រទៅដោយលោកធម៌ តែសេចក្តីសុខក្នុងព្រះនិព្វានគឺជាសេចក្តីសុខ ដែលខ្យល់លោកធម៌បក់



ត្រូវមិនកម្រើកញាប់ញ័រឡើយ ដូចជាព្រះអរហន្តទាំងឡាយ ក្នុងកាលដែលលោកមានព្រះជន្មនៅឡើយ មិនអាចមានធម្មជាតិអ្វីញ៉ាំងសន្តានចិត្តលោក ឱ្យភ័យខ្លាច តក់ស្លុតបានឡើយ ព្រោះសេចក្តីភ័យតក់ស្លុតសេចក្តីសោកគ្រប់ប្រការ ត្រូវបានដាវគឺអរហត្តមគ្គកាត់ផ្តាច់អស់ទៅហើយ ។

**២-អនុបាទិសេសនិព្វានធាតុ** បានដល់និព្វានដែលមិនមានខន្ធ៥ គឺវិបាកខន្ធនិងកម្មជរូបមិនមាននៅសល់ សំដៅយកនិព្វានរបស់ព្រះអរហន្តដែលលោកចូលបរិនិព្វានហើយ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងនឹងភិក្ខុ

ទាំងឡាយថា[១] "ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអរហន្តខីណាស្រព មានព្រហ្មចរិយៈប្រព្រឹត្តរួចហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយដោយលំដាប់ មានសំយោជនៈក្នុងភពអស់ហើយ ផុតស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ការសោយនូវអារម្មណ៏ទាំងពួង មានសុខវេទនាជាដើម ការមិនត្រេកអរដោយកិលេស មានតណ្ហាជាដើម របស់ព្រះអរហន្តនោះ នឹងស្ងប់រម្ងាប់ ឥតកម្រើក ក្នុងអត្តភាពនេះឯង ម្នាលភិក្ខុទាំងឡាយ នេះហៅថា **អនុបាទិសេសនិព្វានធាតុ**" ។

១-ខុទ្ទកនិ. ឥតិវុត្តកៈ. ទុតិយវគ្គ សូត្រទី៧ បិដកលេខ៥៣ ទំព័រទី៥១ ។



**អនុបាទិសេសនិព្វាន** គឺនិព្វានដែលឥតមាននៅសេសសល់ខន្ធ បានដល់សមុច្ឆេទមរណៈ ជាមរណៈចុងក្រោយបង្អស់ក្នុងសង្សារវដ្ត ។

ក្នុងពេលដែលព្រះសម្មាសម្ពុទ្ធ ទ្រង់រំលត់ខន្ធត្រង់ចន្លោះដើមសាលព្រឹក្សទាំងគូ គឺជា**អនុបាទិសេស-និព្វាន** គឺរំលត់អស់ដោយប្រពៃ រំលត់ភពទាំងឡាយ រំលត់ចិត្ត ចេតសិក រូបទាំងអស់ មិនមានការកើតទៀតឡើយ ។

គ្រប់ការកើតទាំងអស់ ទោះជាកំណើតបែបណា ជាមនុស្សឬទេវតា មារ ព្រហ្ម នៅក្នុងភពឋានណាក៏ដោយ ក៏ត្រូវតែមានការស្លាប់ទាល់តែអស់ ឥតមានសេសសល់ ។ ដូច្នេះ មានតែការមិនកើតប៉ុណ្ណោះ

ទើបមិនមានការស្លាប់ **នេះជាច្បាប់ធម្មជាតិ** ។

## និព្វានគឺជាទិសដៅចុងក្រោយនៃជីវិត

**និព្វាន** មិនមែនជាចិត្ត មិនមែនជាព្រលឹង វិញ្ញាណ មិនមែនជាចេតសិក មិនមែនជារូបធាតុ មិនមែនសត្វ បុគ្គលតួខ្លួន ឬថាមិនមែនជាពិភព ដែនដី ប្រទេសឯណានីមួយឡើយ ។ ព្រះនិព្វានជារបស់ដែលមិនមានការកើត និងការរលត់ ព្រោះជា**អសង្ខតធម៌** ។

តាមធម្មតា គ្រប់វត្ថុទាំងអស់ក្រៅអំពីនិព្វាន សុទ្ធតែមានការកើតជាដំបូង បន្ទាប់មកមានការទ្រុឌទ្រោមគ្រាំគ្រា ទីបំផុតត្រូវតែរលត់រលាយអស់ទៅឥត



មានសេសសល់ ព្រោះហេតុអ្វី? ព្រោះរបស់ទាំងនោះសុទ្ធតែមានកំណើតកើតឡើងអំពីបច្ច័យទាំងអស់ ។

ចំណែកព្រះនិព្វាន មានលក្ខណៈផ្សេងអំពីរបស់ដទៃ គឺថា **និព្វានជាអសង្ខតវត្ថុមាន** មិនមានកំណើត មិនមានការអាស្រ័យនឹងរបស់ដទៃ ដោយហេតុថា ព្រះនិព្វានមិនមានការរលត់ ព្រោះមិនមានអ្វីតាក់តែងឱ្យកើតឡើង ។

ដរាបណាសត្វលោក មិនអប់រំចម្រើនបញ្ញាដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានទេ ការកើត ចាស់ ឈឺ ស្លាប់ រមែងមាននៅជាដរាបតទៅទៀត ដែលជាសេចក្តីទុក្ខប្រចាំវដ្តៈ ឥតមានទីបញ្ចប់ ដូច្នេះព្រះនិព្វានទើបជាចំណុចទិសដៅចុងក្រោយនៃជីវិត ។

**អនិច្ចា**សង្ខារធម៌មិនទៀងទាត់ **ទុក្ខា**ប្រាសព្រាត់ព្រោះទ្រាំមិនបាន
**អនត្តា**គួរស្លុតព្រោះមិនមែនប្រាណ **និព្វាន**ទើបក្សាន្តផុតចាកទុក្ខភ័យ ។

សាន~សុជា



## លំដាប់នៃប្រយោជន៍ទាំង៣

**១~ទិដ្ឋធម្មិកត្ថប្រយោជន៍** ជាសេចក្ដីសុខដែលជាប់ទាក់ទងនឹងរូបធម៌ខាងក្រៅ បានដល់ទ្រព្យសម្បត្តិ និងបុគ្គលនៅជុំវិញខ្លួនក្នុងជីវិតបច្ចុប្បន្ន ។

**២~សម្បរាយិកត្ថប្រយោជន៍** ជាសេចក្ដីសុខដែលជាប់ទាក់ទងនឹងនាមធម៌ ជាសភាវធម៌ខាងក្នុង បានដល់ចិត្តសន្តាន រមែងបានសេចក្ដីស្ងប់ចិត្តនាពេលបច្ចុប្បន្ន ព្រោះបានយល់ហេតុផលនៃធម្មជាតិ និងជាពូជសុខទៅក្នុងលោកខាងមុខផង ថែមទាំងជាឧបនិស្ស័យនៃព្រះនិព្វានផង ។

**៣~បរមត្ថប្រយោជន៍** គឺសេចក្ដីសុខជាបរិយោសាន បានដល់សន្តិបទ គឺជាសេចក្ដីសុខស្ងប់ដ៏

កំពូល ដែលសម្រេចបានព្រោះការកសាងសន្សំនូវប្រយោជន៍២ខាងដើមនោះឯង ។

> អត្ថបទចំណារចារប្រយោជន៍បី ដែលខ្ញុំឃ្លាតខ្ចីចងក្រងរចនា ជាកូនសៀវភៅទុកជាតម្រា សង្ខេបខ្លឹមសារចប់តែប៉ុណ្ណេះ ។
>
> សាន~សុជា

# ចប់



**អ្នកមានឧបការៈជួយពិនិត្យអក្ខរាវិរុទ្ធ**

១-ធម្មាចារ្យ គម្ភីរប្បញ្ញោ **ទួច សុធី**

២-ឧទ្ទេសាចារ្យ សីលសំវរោ **ស៊ុំ សាមុត**

៣-សាមណេរ បញ្ញាបរមោ **ឈាត ម៉ិនឆាត**

៤-អ្នកគ្រូ **គីម អំបូរី**

៥-ឧបាសក **ចៅ កុសល**

## សៀវភៅនិងអត្ថបទធម៌
## ដែលខ្ញុំព្រះករុណាអាត្មាភាពបានរៀបរៀង

១-ប្រយោជន៏ ៣ ប្រការ

២-ជីវិត (Life)

៣-បងប្អូនជួបគ្នាមួយគ្រាមានន័យ

៤-ឧបមាគុណព្រះរតនត្រៃម្ភៃពីរប្រការ (កំណាព្យ)

៥-អភិធម្មត្ថសង្គហៈ បរិច្ឆេទទី៤

៦-អភិធម្មសង្គណី តិកមាតិកាសង្ខេប

៧-គោតមប្រវត្តិ (ជាអត្ថបទកំណាព្យសម្រាប់សូត្រនមស្ការ)

៨-ជីវិតពិតជាត្រូវការធម៌

៩-តើនរកមានដែរឬទេ ?

**ព្រះធម៌គឺជាផែនទីនៃជីវិត**



## ប៉ុស្តិ៍វិទ្យុដែលខ្ញុំព្រះករុណាអាត្មាភាព
## កំពុងសម្តែងព្រះធម៌ផ្សព្វផ្សាយនាពេលបច្ចុប្បន្ន

☞ ខេត្តពោធិ៍សាត់ វិទ្យុ FM 100.50 MHz

-ចាប់ពីម៉ោង ៦.៣០ pm ⇨ ៧.00 pm ជារៀងរាល់ល្ងាច ។

☞ ខេត្តពោធិ៍សាត់ វិទ្យុ FM 98.50 MHz

-ចាប់ពីម៉ោង ៧.00 pm ⇨ ៨.00 pm រៀងរាល់ល្ងាចថ្ងៃសីល ។

☞ ខេត្តកំពង់ធំ វិទ្យុ FM 107.30 MHz

-ចាប់ពីម៉ោង ៦.00 am ⇨ ៦.៣០ am ជារៀងរាល់ព្រឹក ។

☞ ក្រុងកំពង់សោម វិទ្យុ FM 92.00 MHz

-ចាប់ពីម៉ោង ៦.៣០ pm ⇨ ៧.00 pm ជារៀងរាល់ល្ងាច ។

**សុខា សទ្ធម្មទេសនា**

ការសម្តែងនូវព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ

# មាតាបិតាមានឈ្មោះ៤យ៉ាង



ភិក្ខុវជិរប្បញ្ញោ **សាន សុជា** និងញោមប្រុសស្រី

១- ជា "ព្រះព្រហ្ម" របស់កូន

២- ជា "បុព្វទេវតា" របស់កូន

៣- ជា "បុព្វាចារ្យ" របស់កូន

៤- ជា "អាហុនេយ្យបុគ្គល" របស់កូន